**កំពង់ផែស្វយ័តក្រុងព្រះសីហនុ**

**ព័ត៌មានហិរញ្ញវត្ថុសង្ខេប (មិនបានធ្វើសវនកម្ម)**
**សម្រាប់ដំណាច់ការិយបរិច្ឆេទ៦ខែ ថ្ងៃទី៣0 ខែមិថុនា ឆ្នាំ២០១៧**

**កំពង់ផែស្វយ័តក្រុងព្រះសីហនុ**

**ព័ត៌មានហិរញ្ញវត្ថុសង្ខេប ( មិនបានធ្វើសវនកម្ម )**
**សម្រាប់ដំណាច់ការិយបរិច្ឆេទ៦ខែ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧**

**មាតិកា** **ទំព័រ**


| | |
|---|---|
| របាយការណ៍ស្តីពីការត្រួតពិនិត្យព័ត៌មានហិរញ្ញវត្ថុសង្ខេប | ១ - ២ |
| របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ | ៣ |
| របាយការណ៍ចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗ | ៤ - ៥ |
| របាយការណ៍បម្រែបម្រួលមូលធន | ៦ |
| របាយការណ៍លំហូរសាច់ប្រាក់ | ៧ |
| កំណត់សម្គាល់ព័ត៌មានហិរញ្ញវត្ថុសង្ខេប | ៨ - ៣៣ |

**របាយការណ៍ស្តីពីការត្រួតពិនិត្យព័ត៌មានហិរញ្ញវត្ថុសង្ខេប**
**ជូនភាគហ៊ុនិក កំពង់ផែស្វយ័តក្រុងព្រះសីហនុ**

## សេចក្តីផ្តើម

យើងខ្ញុំបានធ្វើការត្រួតពិនិត្យលើរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុដែលបានភ្ជាប់មកជាមួយ របស់កំពង់ផែស្វយ័ត ក្រុងព្រះសីហនុ គិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧ របាយការណ៍ចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗ សម្រាប់ដំណាច់ការិយបរិច្ឆេទ៦ខែ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧ របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់ សម្រាប់ដំណាច់ការិយបរិច្ឆេទ។ គណៈគ្រប់គ្រងទទួលខុសត្រូវក្នុងការរៀបចំ និងការបង្ហាញព័ត៌មានហិរញ្ញវត្ថុចន្លោះពេល ដោយស្របទៅតាមស្តង់ដារគណនេយ្យអន្តរជាតិនៃកម្ពុជាលេខ ៣៤ ស្តីពី "របាយការណ៍ហិរញ្ញវត្ថុចន្លោះពេល"។ ការទទួលខុសត្រូវរបស់យើងខ្ញុំគឺបញ្ចេញសេចក្តីសន្និដ្ឋានលើព័ត៌មានហិរញ្ញវត្ថុសង្ខេប ដោយផ្អែកទៅលើការត្រួតពិនិត្យរបស់យើងខ្ញុំ។

## ដែនកំណត់នៃការត្រួតពិនិត្យ

យើងខ្ញុំបានធ្វើការត្រួតពិនិត្យដោយអនុលោមទៅតាមស្តង់ដារអន្តរជាតិនៃកម្ពុជា លើការត្រួតពិនិត្យលេខ ២៤១០ ស្តីពី "ការត្រួតពិនិត្យព័ត៌មានហិរញ្ញវត្ថុចន្លោះពេល ដែលធ្វើឡើងដោយសវនករឯករាជរបស់អង្គភាព"។ ការត្រួតពិនិត្យលើព័ត៌មានហិរញ្ញវត្ថុចន្លោះពេល រួមមានការចោទជាសំណួរទៅអ្នកទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុ និងគណនេយ្យ អនុវត្តការវិភាគ និងនីតិវិធីត្រួតពិនិត្យផ្សេងៗទៀត។ ការត្រួតពិនិត្យមានដែនកំណត់តូចជាងការធ្វើសវនកម្ម ដែលអនុលោមទៅតាមស្តង់ដារអន្តរជាតិស្តីពីសវនកម្មនៃកម្ពុជា។ ជាលទ្ធផលការត្រួតពិនិត្យនេះមិនអាចធ្វើឱ្យយើងខ្ញុំធ្វើការធានាអះអាងអំពីបញ្ហាសំខាន់ៗ ដូចដែលយើងខ្ញុំអាចដឹងក្នុងការធ្វើសវនកម្មនោះទេ។ ដូច្នេះ យើងខ្ញុំមិនបញ្ចេញមតិយោបល់សវនកម្មទេ។

## សេចក្តីសន្និដ្ឋាន

យោងទៅតាមការត្រួតពិនិត្យរបស់យើងខ្ញុំ យើងខ្ញុំកត់សម្គាល់ឃើញថាមិនមានបញ្ហាណាមួយ ដែលធ្វើឱ្យយើងខ្ញុំជឿជាក់ថាព័ត៌មានហិរញ្ញវត្ថុសង្ខេបដែលបានភ្ជាប់មកជាមួយ មិនបានរៀបចំនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់ ដោយស្របទៅតាមស្តង់ដារគណនេយ្យអន្តរជាតិនៃកម្ពុជាលេខ៣៤ ស្តីពី "របាយការណ៍ហិរញ្ញវត្ថុចន្លោះពេល" នោះទេ។

*PricewaterhouseCoopers (Cambodia) Ltd.*
*58C Sihanouk Boulevard, Sangkat Tonle Bassac, Khan Chamkarmon, Phnom Penh, Cambodia*
*T: +855 (0)23 860 606, F: +855(0)23 211 594, www.pwc.com/kh*

**បញ្ហាផ្សេងៗ**

ព័ត៌មានប្រៀបធៀបសម្រាប់របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ គឺផ្អែកទៅតាមរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចសម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦។ ព័ត៌មានប្រៀបធៀបសម្រាប់របាយការណ៍ចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗ របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់ និងកំណត់សម្គាល់របស់វាសម្រាប់ដំណាច់ការិយបរិច្ឆេទ៦ខែ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៦ មិនត្រូវបានធ្វើសវនកម្ម ឬបានត្រួតពិនិត្យទេ។

ជ. PricewaterhouseCoopers (Cambodia) Ltd.

**គុយ លីម**

Partner

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

កាលបរិច្ឆេទ៖ ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៧

## កំពង់ផែស្វយ័តក្រុងព្រះសីហនុ

## របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ
## គិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧

| | កំណត់សម្គាល់ | ៣០ មិថុនា ២០១៧ ពាន់រៀល | ៣១ ធ្នូ ២០១៦ ពាន់រៀល |
|---|---|---|---|
| | | (បានត្រួតពិនិត្យ ប៉ុន្តែមិនបានធ្វើសវនកម្ម) | (បានធ្វើសវនកម្ម) |
| **ទ្រព្យសកម្ម** | | | |
| **ទ្រព្យសកម្មរយៈពេលវែង** | | | |
| ទ្រព្យសម្បត្តិ និងបរិក្ខារ | ៧ | ៧៦០.៧៥៥.៧៣២ | ៧៣៤.៧៤៣.៧៩២ |
| ទ្រព្យសម្បត្តិវិនិយោគ | ៨ | ២៥៦.៩៨៦.១៩៥ | ២៥៩.១៣៥.៩៥០ |
| ទ្រព្យសកម្មអរូបី | ៩ | ៩.០៨៩.១៣៨ | ៩.០២០.៥៩២ |
| ឥណទានបុគ្គលិក | ១០ | ៧.៦៤៥.០៨០ | - |
| | | ១.០៣៤.៤៧៦.១៤៦ | ១.០០២.៩០០.៣៣៤ |
| **ទ្រព្យសកម្មរយៈពេលខ្លី** | | | |
| សន្និធិ | ១១ | ៧.០១៥.៣៨៦ | ៦.៧៩៥.៩១១ |
| គណនីអតិថិជនពាណិជ្ជកម្ម និងគណនីអតិថិជនផ្សេងៗ | ១២ | ៣៤.១០៣.៨៤៦ | ២៥.១០៤.៥៧០ |
| ប្រាក់បញ្ញើនៅធនាគាររយៈពេលខ្លី | ១៣ | ១២.៥៨០.៣៤០ | ១៣.៤៧៩.២២៨ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | ១៤ | ១២៥.៤៧៦.៧៨៦ | ៣៤.៦៥១.៦០៤ |
| | | ១៧៩.១៧៦.៣៥៨ | ៨០.០៣១.៣១៣ |
| **ទ្រព្យសកម្មសរុប** | | ១.២១៣.៦៥២.៥០៤ | ១.០៨២.៩៣១.៦៤៧ |
| | | | |
| **មូលធន និងបំណុល** | | | |
| **មូលធន** | | | |
| ដើមទុន | ១៥ | ៥៣២.១៩៨.៩០៦ | ៤២៨.៨៥៩.៨៣៦ |
| ទុនបម្រុងផ្សេងៗ | ១៦ | ១៤.៩៦៩.៨៦៧ | ១៤.៩៦៩.៨៦៧ |
| ចំណេញរក្សាទុក | | ៨៨.៤៩១.៨៧៥ | ៩០.៧៨៣.៣០៨ |
| **មូលធនសរុប** | | ៦៣៥.៦៦០.៦៤៨ | ៥៣៤.៦១៣.០១១ |
| | | | |
| **បំណុល** | | | |
| **បំណុលរយៈពេលវែង** | | | |
| ប្រាក់កម្ចី | ១៧ | ៤៨៨.៥៥៣.២១៦ | ៤៦៣.២៣៥.៣៧២ |
| កាតព្វកិច្ចអត្ថប្រយោជន៍សោធននិវត្តន៍ | ១៨ | ៤០.៥២៥.១៣៩ | ៤០.៣០១.៤១១ |
| បំណុលពន្ធពន្យារ | | ៣.៧៤៨.៦៤៦ | - |
| ចំណូលពន្យារ | ១៩ | ៦.០៩០.២៨៥ | ៥.៩២៨.៣៣៥ |
| | | ៥៣៨.៩១៧.២៨៦ | ៥០៩.៤៦៥.១១៨ |
| **បំណុលរយៈពេលខ្លី** | | | |
| បំណុលពន្ធលើប្រាក់ចំណេញ | | ១.៩៤១.៩២៩ | ៦.៤៦២.៦៧៥ |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីអ្នកផ្គត់ផ្គង់ផ្សេងៗ | ២០ | ១៦.២១០.៩៦៤ | ១៥.៧១៣.៨៨៧ |
| ប្រាក់កម្ចី | ១៧ | ២០.៧៨៩.៥១២ | ១៦.៥៤៣.៧៣៥ |
| ចំណូលពន្យារ | ១៩ | ១៣២.១៦៥ | ១៣៣.២២១ |
| | | ៣៩.០៧៤.៥៧០ | ៣៨.៨៥៣.៥១៨ |
| **បំណុលសរុប** | | ៥៧៧.៩៩១.៨៥៦ | ៥៤៨.៣១៨.៦៣៦ |
| **មូលធន និងបំណុលសរុប** | | ១.២១៣.៦៥២.៥០៤ | ១.០៨២.៩៣១.៦៤៧ |

កំណត់សម្គាល់ដែលបានភ្ជាប់មកជាមួយពីទំព័រទី ៨ ដល់ ទំព័រទី ៣៣ ជាផ្នែកមួយនៃព័ត៌មានហិរញ្ញវត្ថុសង្ខេបនេះ។

# កំពង់ផែស្វយ័តក្រុងព្រះសីហនុ

## របាយការណ៍ចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗ
## សម្រាប់ដំណាច់ការិយបរិច្ឆេទ៣ខែ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧

| | | ដំណាច់ការិយបរិច្ឆេទ៣ខែ | |
|---|---|---|---|
| | **កំណត់សម្គាល់** | **៣០ មិថុនា ២០១៧ ពាន់រៀល** | **៣០ មិថុនា ២០១៦ ពាន់រៀល** |
| | | (បានត្រួតពិនិត្យ ប៉ុន្តែមិនបានធ្វើសវនកម្ម) | (មិនបានត្រួតពិនិត្យ និងមិនបានធ្វើសវនកម្ម) |
| ចំណូល | | ៥៤.៣៨០.១៤៦ | ៥១.៨៤៧.០២៤ |
| **ចំណាយ** | | | |
| ចំណាយសម្ភារផ្គត់ផ្គង់ | | (១៣.៨១៧.៣៥៨) | (៩.៦៩៧.១៣៣) |
| ចំណាយប្រាក់បៀវត្សរ៍ ប្រាក់ឈ្នួល និងចំណាយពាក់ព័ន្ធ | | (១២.៧៥៤.៦៨៩) | (១២.១៦៣.១៨២) |
| ចំណាយរំលស់ទ្រព្យសម្បត្តិ និងបរិក្ខារ និងរំលស់ទ្រព្យសកម្មអរូបី | | (៥.៨១៥.២៤៣) | (៥.២៦៧.៤៣៦) |
| ចំណាយជួសជុល និងថែទាំ | | (១.៤៣១.៤៧៥) | (១.៩០០.៦០១) |
| ចំណាយផ្សេងៗ | | (៦.២០៥.៧៧០) | (៦.៣៦៦.៩១៤) |
| (ខាត)/ចំណេញផ្សេងៗ – សុទ្ធ | | ៧៨២.០៧៩ | ៩២២.៩០៥ |
| | | (៣៩.២៤២.៤៥៦) | (៣៤.៤៧២.៣៦១) |
| ចំណេញប្រតិបត្តិការ | | ១៥.១៣៧.៦៩០ | ១៧.៣៧៤.៦៦៣ |
| ចំណូលការប្រាក់ | | ៦៧.០៣០ | - |
| ចំណាយការប្រាក់ | | (១១.៨៣៨.៩៨២) | (៤៦.២០៩.៨២០) |
| ចំណាយការប្រាក់ – សុទ្ធ | | (១១.៧៧១.៩៥២) | (៤៦.២០៩.៨២០) |
| **ចំណេញ/(ខាត)មុនបង់ពន្ធលើប្រាក់ចំណេញ** | | ៣.៣៦៥.៧៣៨ | (២៨.៨៣៥.១៥៧) |
| ចំណាយពន្ធលើប្រាក់ចំណេញ | | (២.៨៧៧.០៥៩) | (១.៥២៣.៩៦៨) |
| **ចំណេញ/(ខាត)ក្នុងការិយបរិច្ឆេទ** | | ៤៨៨.៦៧៩ | (៣០.៣៥៩.១២៥) |
| ចំណូលលម្អិតផ្សេងៗ | | | |
| ខ្ទង់ដែលមិនចាត់ថ្នាក់ឡើងវិញក្នុងចំណេញ – ខាត៖ | | - | - |
| **លទ្ធផលលម្អិតសរុបក្នុងការិយបរិច្ឆេទ** | | - | - |
| **ចំណេញ/(ខាត)របស់ភាគហ៊ុនិក** | | ៤៨៨.៦៧៩ | (៣០.៣៥៩.១២៥) |
| **លទ្ធផលលម្អិតសរុបរបស់ភាគហ៊ុនិក** | | ៤៨៨.៦៧៩ | (៣០.៣៥៩.១២៥) |

ចំណេញក្នុងមួយភាគហ៊ុន (ជាប្រាក់រៀល) របស់ភាគហ៊ុនិករបស់ ក.ស.ស ក្នុងអំឡុងការិយបរិច្ឆេទនេះមានដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ចំណេញក្នុងមួយភាគហ៊ុនមូលដ្ឋាន (basic earnings per share) | ២៩ | ៥,៧០ | (៤៧១,៩៤) |
| ចំណេញក្នុងមួយភាគហ៊ុនថយចុះ (diluted earnings per share) | ២៩ | ៥,៧០ | (៤៧១,៩៤) |

កំណត់សម្គាល់ដែលបានភ្ជាប់មកជាមួយពីទំព័រទី ៨ ដល់ ទំព័រទី ៣៣ ជាផ្នែកមួយនៃព័ត៌មានហិរញ្ញវត្ថុសង្ខេបនេះ។

## កំពង់ផែស្វយ័តក្រុងព្រះសីហនុ

## របាយការណ៍ចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗ
## សម្រាប់ដំណាច់ការិយបរិច្ឆេទ៦ខែ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧

| | | ដំណាច់ការិយបរិច្ឆេទ៦ខែ | |
|---|---|---|---|
| | កំណត់សម្គាល់ | ៣០ មិថុនា ២០១៧ ពាន់រៀល | ៣០ មិថុនា ២០១៦ ពាន់រៀល |
| | | (បានត្រួតពិនិត្យ ប៉ុន្តែមិនបានធ្វើសវនកម្ម) | (មិនបានត្រួតពិនិត្យ និងមិនបានធ្វើសវនកម្ម) |
| ចំណូល | ២១ | ១០៤.១៦១.១៥៤ | ១០២.០៦៨.៨៦៦ |
| **ចំណាយ** | | | |
| ចំណាយសម្ភារផ្គត់ផ្គង់ | ២២ | (២៥.០៦៣.៣៧០) | (១៩.២៥២.៤៣៨) |
| ចំណាយប្រាក់បៀវត្សរ៍ ប្រាក់ឈ្នួល និងចំណាយពាក់ព័ន្ធ | ២៣ | (២៤.៦៩១.៣៨៥) | (២៤.២៧៩.៦៤៧) |
| ចំណាយរំលស់ទ្រព្យសម្បត្តិ និងបរិក្ខារ និងរំលស់ទ្រព្យសកម្មអរូបី | ២៤ | (១១.៥៥១.១៨៨) | (១០.៧៦២.៨៧២) |
| ចំណាយជួសជុល និងថែទាំ | | (២.៥៥០.៣៥៩) | (៣.០៤៨.១៥៩) |
| ចំណាយផ្សេងៗ | ២៥ | (១០.៧៣២.០៩០) | (១០.៩៥៣.៨០៨) |
| ចំណេញផ្សេងៗ – សុទ្ធ | ២៦ | ២៦០.០៣៩ | ១២១.១០៥ |
| | | (៧៤.៣២៨.៣៥៣) | (៦៨.១៧៥.៨១៩) |
| ចំណេញប្រតិបត្តិការ | | ២៩.៨៣២.៨០១ | ៣៣.៨៩៣.០៤៧ |
| ចំណូលការប្រាក់ | | ១០៥.៦៥៧ | ២៥.៩៦៥ |
| ចំណាយការប្រាក់ | | (២៤.៩០៤.៨៧៤) | (៦៤.៨៦៧.៣៧២) |
| ចំណាយការប្រាក់ – សុទ្ធ | ២៧ | (២៤.៧៩៩.២១៧) | (៦៤.៨៤១.៤០៧) |
| **ចំណេញ/(ខាត)មុនបង់ពន្ធលើប្រាក់ចំណេញ** | | ៥.០៣៣.៥៨៤ | (៣០.៩៤៨.៣៦០) |
| ចំណាយពន្ធលើប្រាក់ចំណេញ | ២៨ | (៧.៣២៥.០១៧) | (៥.៣១៨.៨៣៤) |
| **ខាតក្នុងការិយបរិច្ឆេទ** | | (២.២៩១.៤៣៣) | (៣៦.២៦៧.១៩៤) |
| ចំណូលលម្អិតផ្សេងៗ | | | |
| ខ្ទង់ដែលមិនចាត់ថ្នាក់ឡើងវិញក្នុងចំណេញ – ខាត៖ | | - | - |
| **លទ្ធផលលម្អិតសរុបក្នុងការិយបរិច្ឆេទ** | | - | - |
| **ខាតរបស់ភាគហ៊ុនិក** | | (២.២៩១.៤៣៣) | (៣៦.២៦៧.១៩៤) |
| **លទ្ធផលលម្អិតសរុបរបស់ភាគហ៊ុនិក** | | (២.២៩១.៤៣៣) | (៣៦.២៦៧.១៩៤) |

ចំណេញក្នុងមួយភាគហ៊ុន (ជាប្រាក់រៀល) របស់ភាគហ៊ុនិករបស់ ក.ស.ស ក្នុងអំឡុងការិយបរិច្ឆេទនេះមានដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ចំណេញក្នុងមួយភាគហ៊ុនមូលដ្ឋាន (basic earnings per share) | ២៩ | (២៦,៧២) | (៥៦៣,៧៨) |
| ចំណេញក្នុងមួយភាគហ៊ុនថយចុះ (diluted earnings per share) | ២៩ | (២៦,៧២) | (៥៦៣,៧៨) |

កំណត់សម្គាល់ដែលបានភ្ជាប់មកជាមួយពីទំព័រទី ៨ ដល់ ទំព័រទី ៣៣ ជាផ្នែកមួយនៃព័ត៌មានហិរញ្ញវត្ថុសង្ខេបនេះ។

## កំពង់ផែស្វយ័តក្រុងព្រះសីហនុ

## របាយការណ៍បម្រែបម្រួលមូលធន
## សម្រាប់ដំណាច់ការិយបរិច្ឆេទ៦ខែ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧

| | ដែលជារបស់ភាគហ៊ុនិក | | | |
|---|---|---|---|---|
| | ភាគហ៊ុន<br>ពាន់រៀល | ទុនបម្រុងផ្សេងៗ<br>ពាន់រៀល | ចំណេញរក្សាទុក<br>ពាន់រៀល | សរុប<br>ពាន់រៀល |
| ដំណាច់ការិយបរិច្ឆេទ៦ខែ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៦<br>(មិនបានត្រួតពិនិត្យ និងមិនបានធ្វើសវនកម្ម) | | | | |
| សមតុល្យនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៦ | ៤២៨.៨៥៩.៨៣៦ | ១២.២៤៥.៤០៥ | ៦៩.០៨៧.២៩៨ | ៥១០.១៩២.៥៣៩ |
| ខាតក្នុងការិយបរិច្ឆេទ | - | - | (៣៦.២៦៧.១៩៤) | (៣៦.២៦៧.១៩៤) |
| ចំណូលលម្អិតសរុបក្នុងការិយបរិច្ឆេទ | - | - | (៣៦.២៦៧.១៩៤) | (៣៦.២៦៧.១៩៤) |
| ភាគលាភបានបង់ | - | - | (១.៣០០.០០០) | (១.៣០០.០០០) |
| សមតុល្យនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៦<br>(បានត្រួតពិនិត្យ ប៉ុន្តែមិនបានធ្វើសវនកម្ម) | ៤២៨.៨៥៩.៨៣៦ | ១២.២៤៥.៤០៥ | ៣១.៥២០.១០៤ | ៤៧២.៦២៥.៣៤៥ |
| ដំណាច់ការិយបរិច្ឆេទ៦ខែ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧<br>(មិនបានត្រួតពិនិត្យ និងមិនបានធ្វើសវនកម្ម) | | | | |
| សមតុល្យនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៧ | ៤២៨.៨៥៩.៨៣៦ | ១៤.៩៦៩.៨៦៧ | ៩០.៧៨៣.៣០៨ | ៥៣៤.៦១៣.០១១ |
| ខាតក្នុងការិយបរិច្ឆេទ | - | | (២.២៩១.៤៣៣) | (២.២៩១.៤៣៣) |
| ចំណូលលម្អិតសរុបក្នុងការិយបរិច្ឆេទ | - | - | (២.២៩១.៤៣៣) | (២.២៩១.៤៣៣) |
| សាច់ប្រាក់បានពីការចេញផ្សាយភាគហ៊ុន | ១០៣.៣៣៩.០៧០ | - | - | ១០៣.៣៣៩.០៧០ |
| សមតុល្យនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧<br>(បានត្រួតពិនិត្យ ប៉ុន្តែមិនបានធ្វើសវនកម្ម) | ៥៣២.១៩៨.៩០៦ | ១៤.៩៦៩.៨៦៧ | ៨៨.៤៩១.៨៧៥ | ៦៣៥.៦៦០.៦៤៨ |

កំណត់សម្គាល់ដែលបានភ្ជាប់មកជាមួយពីទំព័រទី ៨ ដល់ ទំព័រទី ៣៣ ជាផ្នែកមួយនៃព័ត៌មានហិរញ្ញវត្ថុសង្ខេបនេះ។

# កំពង់ផែស្វយ័តក្រុងព្រះសីហនុ

## របាយការណ៍លំហូរសាច់ប្រាក់
## សម្រាប់ដំណាច់ការិយបរិច្ឆេទ៦ខែ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧

| | កំណត់សម្គាល់ | ដំណាច់ការិយបរិច្ឆេទ៦ខែ<br>៣០ មិថុនា ២០១៧<br>ពាន់រៀល<br>(បានត្រួតពិនិត្យ ប៉ុន្តែមិនបានធ្វើសវនកម្ម) | <br>៣០ មិថុនា ២០១៦<br>ពាន់រៀល<br>(មិនបានត្រួតពិនិត្យ និងមិនបានធ្វើសវនកម្ម) |
|---|---|---|---|
| **លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | |
| សាច់ប្រាក់បានពីប្រតិបត្តិការ | ៣០ | ៣៧.៤៩៤.៨៥៨ | ៣៨.០៣៤.១៩៥ |
| ពន្ធលើប្រាក់ចំណេញបានបង់ | | (៨.០៩៧.១១៧) | (៥.១៩៩.៤១២) |
| កាតព្វកិច្ចអត្ថប្រយោជន៍សោធននិវត្តន៍បានបង់ | ១៨ | (១.៨៥៣.២៧២) | (១.៤៧០.៣០៣) |
| សាច់ប្រាក់បានមកពីសកម្មភាពប្រតិបត្តិការ | | ២៧.៥៤៤.៤៦៩ | ៣១.៣៦៤.៤៨០ |
| **លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | |
| ការទិញទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | ៧ | (៣៤.០០៥.១៣៨) | (៥៣.០៤៨.២៤៥) |
| ការទិញទ្រព្យសម្បត្តិវិនិយោគ | ៨ | (៨៨១.៧៥៨) | (៤៤៩.៩៥៧) |
| ការទិញទ្រព្យសកម្មអរូបី | ៩ | (៥៩៥.០២៣) | (៧២៩.៣៨៨) |
| ឥណទានបុគ្គលិក | | (១០.២៦៦.៩០៤) | - |
| ការដាក់ប្រាក់បញ្ញើនៅធនាគាររយៈពេលខ្លី | | ៨៩៨.៨៨៨ | (២១២.១៨១) |
| ការប្រាក់បានទទួល | | ១៣២.៨៣២ | ២៥.៩៦៥ |
| សាច់ប្រាក់បានប្រើក្នុងសកម្មភាពវិនិយោគ | | (៤៤.៧១៧.១០៤) | (៥៤.៤១៣.៨០៦) |
| **លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | |
| សាច់ប្រាក់បានពីការចេញផ្សាយភាគហ៊ុន | ១៥ | ១០៣.៣៣៩.០៧០ | - |
| ភាគលាភបានបង់ | | - | (១.៣០០.០០០) |
| សាច់ប្រាក់បានពីប្រាក់កម្ចី | | ១៦.៥២៣.២១១ | ១៥.១៩៦.៥១៦ |
| ការសងប្រាក់កម្ចី | | (៧.១៣៨.០៩១) | (៧.៣៥៧.២២៨) |
| ចំណាយការប្រាក់បានបង់ | | (៤.៧២៦.៣៧៣) | (៥.៩៣៤.៥៩២) |
| សាច់ប្រាក់បានពីសកម្មភាពហិរញ្ញប្បទាន | | ១០៧.៩៩៧.៨១៧ | ៦០៤.៦៩៦ |
| **កំណើន/(តំហយ)សាច់ប្រាក់ និងសាច់ប្រាក់សមមូលសុទ្ធ** | | ៩០.៨២៥.១៨២ | (២២.៤៤៤.៦៣០) |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូលដើមការិយបរិច្ឆេទ | | ៣៤.៦៥១.៦០៤ | ៤៥.២២៩.៨០៤ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលដំណាច់ការិយបរិច្ឆេទ** | | ១២៥.៤៧៦.៧៨៦ | ២២.៧៨៥.១៧៤ |

កំណត់សម្គាល់ដែលបានភ្ជាប់មកជាមួយពីទំព័រទី ៨ ដល់ ទំព័រទី ៣៣ ជាផ្នែកមួយនៃព័ត៌មានហិរញ្ញវត្ថុសង្ខេបនេះ។

**កំពង់ផែស្វយ័តក្រុងព្រះសីហនុ**

**កំណត់សម្គាល់ព័ត៌មានហិរញ្ញវត្ថុសង្ខេប (មិនបានធ្វើសវនកម្ម)**
**សម្រាប់ដំណាច់ការិយបរិច្ឆេទ៦ខែ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧**

## ១. ព័ត៌មានទូទៅ

កំពង់ផែស្វយ័តក្រុងព្រះសីហនុ (ហៅកាត់ថា "ក.ស.ស") គឺជាគ្រឹះស្ថានស្វយ័តសាធារណៈ ដែលស្ថិតក្រោមការគ្រប់គ្រងផ្នែកបច្ចេកទេសរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន និងស្ថិតក្រោមការគ្រប់គ្រងផ្នែកហិរញ្ញវត្ថុ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយមានការិយាល័យកណ្តាលនៅក្រុងព្រះសីហនុ ព្រះរាជាណាចក្រកម្ពុជា។

ក.ស.ស គឺជានីតិអង្គភាពដែលមានលក្ខណៈស្វយ័តទាំងផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ និងត្រូវបានបង្កើតឡើងដោយអនុលោមទៅតាមអនុក្រឹតលេខ ៥០ អនក្រ.បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨ ដែលបានផ្តល់ស្ថានភាពឱ្យក្រុមហ៊ុនជាសហគ្រាសសាធារណៈ។

ក.ស.ស បានចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្ម ក្រោមវិញ្ញាបនបត្រចុះបញ្ជីលេខ Co.៤៧៨៤ET/២០១៧ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៧។ បច្ចុប្បន្ននេះ ក.ស.ស គឺជាកំពង់ផែសមុទ្រអន្តរជាតិ និងជាកំពង់ផែពាណិជ្ជកម្មតែមួយគត់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ អនុលោមទៅតាមអនុក្រឹតស្តីពីការបង្កើតកំពង់ផែស្វយ័តក្រុងព្រះសីហនុ បេសកកម្មរបស់ ក.ស.ស គឺផ្តល់សេវាកំពង់ផែសមុទ្រ និងសកម្មភាពផ្សេងៗដែលពាក់ព័ន្ធនឹងសេវាកំពង់ផែសមុទ្រ ដូចខាងក្រោម៖

- កណ្តាលការកិច្ចនាំនាវាចេញ-ចូល និងផ្តល់ភស្តុភាដល់នាវា
- លើកដាក់ ផ្ទេរផ្ទុក និងដឹកជញ្ជូនទំនិញ
- ការងារថែរក្សា ស្តុកទំនិញ ឃ្លាំង-ទីលាន
- ការងារអភិវឌ្ឍន៍ ស្តារ និងពង្រីកហេដ្ឋារចនាសម្ព័ន្ធ ក.ស.ស ដែលមានស្រាប់
- ទទួលខុសត្រូវ និងចាត់ចែងលើការងារការពារសុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់ក្នុងតំបន់គ្រប់គ្រង
- ប្រកាន់គោលការណ៍ និងរបៀបកិច្ចការដូចនឹងការប្រកបអាជីវកម្ម
- គ្រប់គ្រងដឹកនាំ និងចាត់ចែងសកម្មភាពឱ្យមានប្រសិទ្ធភាព និងមានការរីកចម្រើន

ក្នុងឋានៈជាស្ថាប័នសាធារណៈ ក.ស.ស ទទួលពីរដ្ឋនូវអំណាច និងកាតព្វកិច្ចទាំងឡាយ ដើម្បីបំពេញបេសកកម្មស្របតាមកម្មវត្ថុរបស់ខ្លួន ។

ការិយាល័យចុះបញ្ជីរបស់ ក.ស.ស មានទីតាំងស្ថិតនៅតិរវិថី សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ព្រះរាជាណាចក្រកម្ពុជា។

ក្រុមប្រឹក្សាភិបាលអនុម័តឱ្យចេញផ្សាយព័ត៌មានហិរញ្ញវត្ថុសង្ខេប នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៧។

ព័ត៌មានហិរញ្ញវត្ថុសង្ខេបសម្រាប់ដំណាច់ការិយបរិច្ឆេទ៦ខែ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧ ត្រូវបានត្រួតពិនិត្យ ប៉ុន្តែមិនត្រូវបានធ្វើសវនកម្មទេ។

## ២. មូលដ្ឋានក្នុងការរៀបចំព័ត៌មានហិរញ្ញវត្ថុសង្ខេប

ព័ត៌មានហិរញ្ញវត្ថុសង្ខេបសម្រាប់ដំណាច់ការិយបរិច្ឆេទ៦ខែ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧ ត្រូវបានរៀបចំឡើងដោយអនុលោមទៅតាមស្តង់ដារគណនេយ្យអន្តរជាតិកម្ពុជា លេខ៣៤ ស្តីពី "របាយការណ៍ហិរញ្ញវត្ថុចន្លោះពេល" ("CIAS 34")។

ព័ត៌មានហិរញ្ញវត្ថុសង្ខេបនេះមិនរួមបញ្ចូលនូវរាល់កំណត់សម្គាល់គ្រប់ប្រភេទទាំងអស់ ដូចបានបង្ហាញជាធម្មតានៅក្នុងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មប្រចាំឆ្នាំទេ។ ដូចនេះ ព័ត៌មានហិរញ្ញវត្ថុសង្ខេបនេះគួរត្រូវបានអានភ្ជាប់ជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ដែលត្រូវបានរៀបចំឡើងដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("CIFRS")។ គោលការណ៍គណនេយ្យសំខាន់ៗដែលបានប្រើក្នុងការរៀបចំព័ត៌មានហិរញ្ញវត្ថុសង្ខេបនេះ គឺដូចទៅនឹងគោលការណ៍គណនេយ្យសំខាន់ៗដែលបានប្រើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចសម្រាប់ឆ្នាំ២០១៦។

ក.ស.ស គឺជាអង្គភាពដែលមានការទទួលខុសត្រូវជាសាធារណៈ ដោយសារ ក.ស.ស បានចុះបញ្ជីក្នុងក្រុមហ៊ុនមូលបត្រកម្ពុជា នៅថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៧។ យោងតាមតម្រូវការរបស់គណៈកម្មការមូលបត្រកម្ពុជា ក.ស.ស ត្រូវរៀបចំ និងដាក់ព័ត៌មានហិរញ្ញវត្ថុសម្រាប់ដំណាច់ការិយបរិច្ឆេទ៦ខែ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧ ជូនគណៈកម្មការមូលបត្រកម្ពុជា ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("CIFRS")។

## ៣. គោលការណ៍គណនេយ្យ

លើកលែងតែស្តង់ដារគណនេយ្យដូចបានបង្ហាញខាងក្រោម គោលការណ៍គណនេយ្យដែលបានអនុវត្ត និងវិធីសាស្ត្រគណនាដែលបានប្រើប្រាស់ក្នុងការរៀបចំព័ត៌មានហិរញ្ញវត្ថុសង្ខេប គឺដូចគ្នាទៅនឹងគោលការណ៍គណនេយ្យ និងវិធីសាស្ត្រគណនាដែលបានប្រើប្រាស់ក្នុងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្ម សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦។

ក.ស.ស បានអនុវត្តវិសោធនកម្មស្តង់ដារគណនេយ្យដូចខាងក្រោមនេះ សម្រាប់ការិយបរិច្ឆេទគណនេយ្យដែលចាប់ផ្តើមនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៧៖

| | |
|---|---|
| CIFRS (វិសោធនកម្ម) | ការកែលម្អប្រចាំឆ្នាំ ចំពោះស្តង់ដារ CIFRS Cycle 2014-2016 |
| CIAS 7 | ការលាតត្រដាងលើកដំបូងនៃវិសោធនកម្ម CIAS 7 |
| CIAS 12 | វិសោធនកម្ម CIAS 12 ស្តីពី "ការទទួលស្គាល់ពន្ធពន្យារទ្រព្យសកម្ម សម្រាប់ការខាតបង់ដែលមិនទាន់កត់ត្រា" |
| CIAS 40 | វិសោធនកម្ម CIAS 40 ស្តីពី "ការផ្ទេរទ្រព្យសម្បត្តិវិនិយោគ" |

ការអនុវត្តវិសោធនកម្មស្តង់ដារគណនេយ្យទាំងនេះ មិនមានផលប៉ះពាល់ជាសារវន្តទៅលើលទ្ធផល និងស្ថានភាពហិរញ្ញវត្ថុរបស់ ក.ស.ស ទេ។

**កំពង់ផែស្វយ័តក្រុងព្រះសីហនុ**

**កំណត់សម្គាល់ព័ត៌មានហិរញ្ញវត្ថុសង្ខេប ( មិនបានធ្វើសវនកម្ម )**
**សម្រាប់ដំណាច់ការិយបរិច្ឆេទ៦ខែ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧**

## ៤. ការប៉ាន់ស្មានរបស់គណៈគ្រប់គ្រង

ការរៀបចំព័ត៌មានហិរញ្ញវត្ថុសង្ខេប តម្រូវឱ្យគណៈគ្រប់គ្រងធ្វើការវិនិច្ឆ័យ ការប៉ាន់ស្មាន ការសន្មត ដែលមានផលប៉ះពាល់ដល់ការអនុវត្តគោលការណ៍គណនេយ្យ និងចំនួនទឹកប្រាក់របស់ទ្រព្យសកម្ម បំណុល ចំណូល និងចំណាយដែលបានរាយការណ៍។

ក្នុងការរៀបចំព័ត៌មានហិរញ្ញវត្ថុសង្ខេប ការវិនិច្ឆ័យសំខាន់ដែលគណៈគ្រប់គ្រងបានធ្វើឡើង ក្នុងការអនុវត្ត គោលការណ៍គណនេយ្យរបស់ ក.ស.ស និងប្រភពសំខាន់ៗក្នុងការប៉ាន់ស្មានភាពមិនប្រាកដប្រជា គឺដូចគ្នាទៅនឹងការវិនិច្ឆ័យដែលបានអនុវត្តក្នុងរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦។

## ៥. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ

### ៥.១ កត្តាហានិភ័យហិរញ្ញវត្ថុផ្សេងៗ

ក.ស.ស ត្រូវប្រឈមមុខនឹងហានិភ័យផ្សេងៗដូចជា ហានិភ័យទីផ្សារ (រួមមានហានិភ័យការប្តូររូបិយប័ណ្ណ និង ហានិភ័យអត្រាការប្រាក់) ហានិភ័យឥណទាន និងហានិភ័យសាច់ប្រាក់ងាយស្រួល។

ការរៀបចំព័ត៌មានហិរញ្ញវត្ថុសង្ខេប មិនតម្រូវឱ្យរួមបញ្ចូលនូវព័ត៌មាន និងការលាតត្រដាងហានិភ័យហិរញ្ញវត្ថុទាំងអស់ដូចការការរៀបចំរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មប្រចាំឆ្នាំទេ ហើយគួរអានភ្ជាប់ជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្ម សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦។

### ៥.២ តម្លៃសមស្របរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុវាស់វែងតាមថ្លៃដើមដករំលស់

វិធីសាស្រ្ត និងការសន្មត ដែលបានប្រើក្នុងការប៉ាន់ស្មានតម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុ មានដូចខាងក្រោម៖

(ក) *សាច់ប្រាក់ និងសាច់ប្រាក់សមមូល និងការវិនិយោគរយៈពេលខ្លី* - តម្លៃយោងនៃគណនីទាំងនេះ មានតម្លៃប្រហាក់ប្រហែលនឹងតម្លៃសមស្រប ដោយសារវាមានរយៈពេលខ្លី។

(ខ) *គណនីអតិថិជន និងគណនីអ្នកផ្គត់ផ្គង់ផ្សេងៗ* - តម្លៃយោងដកសំវិធានធនដែលបណ្តាលមកពីការថយចុះតម្លៃមានតម្លៃប្រហាក់ប្រហែលនឹងតម្លៃសមស្រប ដោយសារគណនីទាំងនេះស្ថិតនៅក្រោមលក្ខខណ្ឌឥណទានធម្មតា និងមានរយៈពេលខ្លី។

(គ) *ប្រាក់កម្ចី* - តម្លៃសមស្របនៃប្រាក់កម្ចីត្រូវប៉ាន់ស្មានដោយធ្វើអប្បហារលើលំហូរសាច់ប្រាក់ក្នុងកិច្ចសន្យានាពេលអនាគត ដោយប្រើអត្រាប្រាក់កម្ចីនាដំណាច់ឆ្នាំ។

ឧបករណ៍ហិរញ្ញវត្ថុដែលវាស់វែងតាមតម្លៃសមស្រប ត្រូវបានវិភាគទៅតាមឋានានុក្រមនៃការវាស់វែងតម្លៃសមស្របដូចខាងក្រោម៖

កម្រិត ១ តម្លៃលក់ក្នុងទីផ្សារសកម្ម (មិនកែតម្រូវ) ចំពោះទ្រព្យសកម្ម ឬបំណុលដែលអាចកំណត់បាន។ ក.ស.ស មិនមានកាន់កាប់មូលបត្រចុះបញ្ជីទេ។

កម្រិត ២ ធាតុចូលផ្សេងៗ ក្រៅពីតម្លៃលក់ដែលបានរួមបញ្ចូលក្នុង កម្រិត ១ ដែលអាចអង្កេតទ្រព្យសកម្ម ឬ បំណុល បានដោយផ្ទាល់ (តាមថ្លៃកំណត់) ឬ ដោយប្រយោល (តាមថ្លៃ derived from prices)

កម្រិត ៣ ធាតុចូលចំពោះទ្រព្យសកម្ម ឬបំណុល ដែលមិនអាស្រ័យលើទិន្នន័យលើទីផ្សារដែលអាចសង្កេតបាន (ដែលជាធាតុចូលដែលមិនអាចអង្កេតបាន)។

ក្នុងអំឡុងឆ្នាំនេះ មិនមានការផ្ទេររវាងកម្រិតខុសៗគ្នានៃឋានានុក្រមតម្លៃសមស្របទេ។

**កំណត់សម្គាល់ព័ត៌មានហិរញ្ញវត្ថុសង្ខេប ( មិនបានធ្វើសវនកម្ម )**
**សម្រាប់ដំណាច់ការិយបរិច្ឆេទ៦ខែ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧**

## ៦. ព័ត៌មានប្រតិបត្តិការតាមផ្នែក

ក.ស.ស មានប្រតិបត្តិការតាមផ្នែកដែលត្រូវរាយការណ៍គឺ សេវាផ្នែកកំពង់ផែ។ ប្រធានអ្នកសម្រេចចិត្តផ្នែកប្រតិបត្តិការ (ក្រុមគណៈគ្រប់គ្រង) ត្រួតពិនិត្យរបាយការណ៍គ្រប់គ្រងផ្ទៃក្នុង ដែលបានរាយការណ៍អំពីលទ្ធផលនៃសេវាផ្នែកកំពង់ផែទាំងមូល ដើម្បីវាយតម្លៃអំពីលទ្ធផល និងការបែងចែកធនធាន។ ប្រធានអ្នកសម្រេចចិត្តផ្នែកប្រតិបត្តិការវាយតម្លៃអំពីលទ្ធផលនៃប្រតិបត្តិការតាមផ្នែក ដោយផ្អែកទៅលើទំហំប្រាក់ចំណូលដុល ចំណេញមុនបង់ពន្ធ និងចំណេញសុទ្ធធៀបនឹងការិយបរិច្ឆេទមុនៗ។ លើសពីនេះ ក.ស.ស ក៏បានបង្កើតតំបន់សេដ្ឋកិច្ចពិសេសថ្មី ដែលកំពុងធ្វើប្រតិបត្តិការនៅដំណាក់កាលដំបូង សូមយោងទៅកំណត់សម្គាល់ ៧។

ប្រាក់ចំណូលទាំងអស់បានមកពីអតិថិជនខាងក្រៅ។ ក.ស.ស មានទីតាំងស្ថិតនៅក្នុងខេត្តព្រះសីហនុ ហើយរាល់ការលក់ទាំងអស់មានប្រភពចេញពីខេត្តព្រះសីហនុ និងតំបន់ជុំវិញ។

# កំណត់សម្គាល់ព័ត៌មានហិរញ្ញវត្ថុសង្ខេប (មិនបានធ្វើសវនកម្ម)
# សម្រាប់ដំណាច់ការិយបរិច្ឆេទ៦ខែ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧

## ៧. ទ្រព្យសម្បត្តិ និងបរិក្ខារ

| | ដីធ្លី ពាន់រៀល | ការកែលម្អដីធ្លី ពាន់រៀល | អគារ ពាន់រៀល | សម្ភារកំពង់ផែ ពាន់រៀល | បរិក្ខារ បច្ចេកទេស ពាន់រៀល | បរិក្ខារផ្សេងៗ ពាន់រៀល | គ្រឿងសង្ហារិម និងបរិក្ខារភ្ជាប់ ពាន់រៀល | កុំព្យូទ័រ និងបរិក្ខារ ការិយាល័យ ពាន់រៀល | យានយន្ត ពាន់រៀល | បរិក្ខារ កំពង់ផែសមុទ្រ ពាន់រៀល | ការងារកំពុង ដំណើរការ ពាន់រៀល | សម្ភារទេចខ្ទប់ ពាន់រៀល | សរុប ពាន់រៀល |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ | | | | | | | | | | | | | |
| ថ្លៃដើម | ២៥២.០៤៥.៦៤០ | ៤៨.៩០៧.៦៤០ | ២៣១.៤៨៤.១៧៦ | ១១៤.២៩០.៥៧៦ | ២២.៤៥០.២៤១ | ១.២៨៨.៧៩៥ | ២.០៦១.៣៦២ | ៦.៤៩១.៥០៨ | ២៥.៥៨០.៩៩៨ | ២៣៦.៤៩០.៩២១ | ១៦៦.១៨២.៥២៦ | ១.២៦០.៦៨៤ | ១.១០៨.៥៣៥.០៦៧ |
| រំលស់បង្គរ | - | (២៣.៧៥៤.៨៨០) | (៧៤.៧៨០.១២២) | (១១៣.៣៩០.៦២៩) | (១៥.៦៦៧.៩០២) | (៨២៤.៨៥៣) | (១.៦៣៤.៤២៤) | (៣.១៥១.៥៤៤) | (១៦.៩២៨.៨៧៩) | (១២២.៦៦៣.៥៩០) | - | (៩៩៤.៤៥២) | (៣៧៣.៧៩១.២៧៥) |
| តម្លៃចុះបញ្ជីសុទ្ធ | ២៥២.០៤៥.៦៤០ | ២៥.១៥២.៧៦០ | ១៥៦.៧០៤.០៥៤ | ៨៩៩.៩៤៧ | ៦.៧៨២.៣៣៩ | ៤៦៣.៩៤២ | ៤២៦.៩៣៨ | ៣.៣៣៩.៩៦៤ | ៨.៦៥២.១១៩ | ១១៣.៨២៧.៣៣១ | ១៦៦.១៨២.៥២៦ | ២៦៦.២៣២ | ៧៣៤.៧៤៣.៧៩២ |
| ដំណាច់ការិយបរិច្ឆេទ៦ខែ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧ (បានត្រួតពិនិត្យ ប៉ុន្តែមិនបានធ្វើសវនកម្ម) | | | | | | | | | | | | | |
| តម្លៃចុះបញ្ជីសុទ្ធដើមគ្រា | ២៥២.០៤៥.៦៤០ | ២៥.១៥២.៧៦០ | ១៥៦.៧០៤.០៥៤ | ៨៩៩.៩៤៧ | ៦.៧៨២.៣៣៩ | ៣៧៧.០០៩ | ៤២៦.៩៣៨ | ៣.៣៣៩.៩៦៤ | ៨.៦៥២.១១៩ | ១១៣.៨២៧.៣៣១ | ១៦៦.១៨២.៥២៦ | ៣៥៣.១៦៥ | ៧៣៤.៧៤៣.៧៩២ |
| ទិញបន្ថែម | - | ៣៣៦.៧០១ | ៥១៦.៣៣០ | - | - | - | ៨៨.១៦០ | ២២.៦៤៤ | ៤.៣២៨.៩៦១ | - | ២៨.៤៤២.៩៨១ | ២៦៩.៣៦១ | ៣៤.០០៥.១៣៨ |
| រំលស់ | - | (៥១៦.៩៤៧) | (២.៣៦៨.៥០២) | (៤៨.៥២៨) | (៦៧៥.២៩២) | (២៩.០៤៤) | (១៣៤.៩៩៩) | (៥៨៥.៣៨៦) | (៥៣២.២៣៧) | (២.៩៤៨.១៣៥) | - | (១៥៤.១២៨) | (៧.៩៩៣.១៩៨) |
| តម្លៃចុះបញ្ជីសុទ្ធចុងគ្រា | ២៥២.០៤៥.៦៤០ | ២៤.៩៧២.៥១៤ | ១៥៤.៨៥១.៨៨២ | ៨៥១.៤១៩ | ៦.១០៧.០៤៧ | ៣៤៧.៩៦៥ | ៣៨០.០៩៩ | ២.៧៧៧.២២២ | ១២.៤៤៨.៨៤៣ | ១១០.៨៧៩.១៩៦ | ១៩៤.៦២៥.៥០៧ | ៤៦៨.៣៩៨ | ៧៦០.៧៥៥.៧៣២ |
| នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧ | | | | | | | | | | | | | |
| ថ្លៃដើម | ២៥២.០៤៥.៦៤០ | ៤៩.២៤៤.៣៤១ | ២៣២.០០០.៥០៦ | ១១៤.២៩០.៥៧៦ | ២២.៤៥០.២៤១ | ១.២០១.២៥៤ | ២.១៤៩.៥២២ | ៦.៥១៤.១៥២ | ២៩.៩០៩.៩៥៩ | ២៣៦.៤៩០.៩២១ | ១៩៤.៦២៥.៥០៧ | ១.៦១៧.៥៨៦ | ១.១៤២.៥៤០.២០៥ |
| រំលស់បង្គរ | - | (២៤.២៧១.៨២៧) | (៧៧.១៤៨.៦២៤) | (១១៣.៤៣៩.១៥៧) | (១៦.៣៤៣.១៩៤) | (៨៥៣.២៨៩) | (១.៧៦៩.៤២៣) | (៣.៧៣៦.៩៣០) | (១៧.៤៦១.១១៦) | (១២៥.៦១១.៧២៥) | - | (១.១៤៩.១៨៨) | (៣៨១.៧៨៤.៤៧៣) |
| តម្លៃចុះបញ្ជីសុទ្ធ (បានត្រួតពិនិត្យ ប៉ុន្តែមិនបានធ្វើសវនកម្ម) | ២៥២.០៤៥.៦៤០ | ២៤.៩៧២.៥១៤ | ១៥៤.៨៥១.៨៨២ | ៨៥១.៤១៩ | ៦.១០៧.០៤៧ | ៣៤៧.៩៦៥ | ៣៨០.០៩៩ | ២.៧៧៧.២២២ | ១២.៤៤៨.៨៤៣ | ១១០.៨៧៩.១៩៦ | ១៩៤.៦២៥.៥០៧ | ៤៦៨.៣៩៨ | ៧៦០.៧៥៥.៧៣២ |

**កំពង់ផែស្វយ័តក្រុងព្រះសីហនុ**

**កំណត់សម្គាល់ព័ត៌មានហិរញ្ញវត្ថុសង្ខេប (មិនបានធ្វើសវនកម្ម)**
**សម្រាប់ដំណាច់ការិយបរិច្ឆេទ៦ខែ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧**

## ៨. ទ្រព្យសម្បត្តិវិនិយោគ

| | ដីធ្លី (*) ពាន់រៀល | អគារ ពាន់រៀល | ទីលានកំពង់ផែ ពាន់រៀល | ផ្លូវថ្នល់ ពាន់រៀល | ប្រព័ន្ធទឹក ពាន់រៀល | បរិក្ខារផ្សេងៗ ពាន់រៀល | កំពុងសាងសង់ ពាន់រៀល | សរុប ពាន់រៀល |
|---|---|---|---|---|---|---|---|---|
| នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ | | | | | | | | |
| ថ្លៃដើម | ១០៣.០១៤.០១៦ | ៧១.២០២.៦៦៣ | ១៥.៨៥៨.៦៩៨ | ១២.៣៩៩.៥១៦ | ៤៦.៥០២.៥៦២ | ២៨.០៩១.៨៨១ | - | ២៧៧.០៦៩.៣៣៦ |
| រំលស់បង្គរ | - | (៨.៦១៥.៤៣៩) | (៦៦៦.៨៣៦) | (៥២១.៣៨២) | (១.៩៥៥.៣៦៨) | (៦.១៧៤.៣៦១) | - | (១៧.៩៣៣.៣៨៦) |
| តម្លៃចុះបញ្ជីសុទ្ធ | ១០៣.០១៤.០១៦ | ៦២.៥៨៧.២២៤ | ១៥.១៩១.៨៦២ | ១១.៨៧៨.១៣៤ | ៤៤.៥៤៧.១៩៤ | ២១.៩១៧.៥២០ | - | ២៥៩.១៣៥.៩៥០ |
| ដំណាច់ការិយបរិច្ឆេទ៦ខែ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧ (បានត្រួតពិនិត្យ ប៉ុន្តែមិនបានធ្វើសវនកម្ម) | | | | | | | | |
| តម្លៃចុះបញ្ជីសុទ្ធដើមគ្រា | ១០៣.០១៤.០១៦ | ៦២.៥៨៧.២២៤ | ១៥.១៩១.៨៦២ | ១១.៨៧៨.១៣៤ | ៤៤.៥៤៧.១៩៤ | ២១.៩១៧.៥២០ | - | ២៥៩.១៣៥.៩៥០ |
| ទិញបន្ថែម | ៨៩.៧៥៩ | ៣៥១.៤៤៥ | - | - | - | - | ៤៤០.៥៥៤ | ៨៨១.៧៥៨ |
| រំលស់ | - | (៧០៤.០៩១) | (១៦១.៦១៦) | (១២៦.៣៦៣) | (៤៧៣.៩០៦) | (១.៥៦៥.៥៣៧) | - | (៣.០៣១.៥១៣) |
| តម្លៃចុះបញ្ជីសុទ្ធចុងគ្រា | ១០៣.១០៣.៧៧៥ | ៦២.២៣៤.៥៧៨ | ១៥.០៣០.២៤៦ | ១១.៧៥១.៧៧១ | ៤៤.០៧៣.២៨៨ | ២០.៣៥១.៩៨៣ | ៤៤០.៥៥៤ | ២៥៦.៩៨៦.១៩៥ |
| នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧ | | | | | | | | |
| ថ្លៃដើម | ១០៣.១០៣.៧៧៥ | ៧១.៥៥៤.១០៨ | ១៥.៨៥៨.៦៩៨ | ១២.៣៩៩.៥១៦ | ៤៦.៥០២.៥៦២ | ២៨.០៩១.៨៨១ | ៤៤០.៥៥៤ | ២៧៧.៩៥១.០៩៤ |
| រំលស់បង្គរ | - | (៩.៣១៩.៥៣០) | (៨២៨.៤៥២) | (៦៤៧.៧៤៥) | (២.៤២៩.២៧៤) | (៧.៧៣៩.៨៩៨) | - | (២០.៩៦៤.៨៩៩) |
| តម្លៃចុះបញ្ជីសុទ្ធ (បានត្រួតពិនិត្យ ប៉ុន្តែមិនបានធ្វើសវនកម្ម) | ១០៣.១០៣.៧៧៥ | ៦២.២៣៤.៥៧៨ | ១៥.០៣០.២៤៦ | ១១.៧៥១.៧៧១ | ៤៤.០៧៣.២៨៨ | ២០.៣៥១.៩៨៣ | ៤៤០.៥៥៤ | ២៥៦.៩៨៦.១៩៥ |

**កំណត់សម្គាល់ព័ត៌មានហិរញ្ញវត្ថុសង្ខេប (មិនបានធ្វើសវនកម្ម)**
**សម្រាប់ដំណាច់ការិយបរិច្ឆេទ៦ខែ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧**

## ៨. ទ្រព្យសម្បត្តិវិនិយោគ (ត)

ចំនួនទឹកប្រាក់ខាងក្រោមនេះ ត្រូវបានកត់ត្រានៅក្នុងរបាយការណ៍ចំណេញ-ខាត ៖

| | ដំណាច់ការិយបរិច្ឆេទ៦ខែ | |
|---|---|---|
| | ៣០ មិថុនា ២០១៧<br>ពាន់រៀល<br>(បានត្រួតពិនិត្យ ប៉ុន្តែមិនបានធ្វើសវនកម្ម) | ៣០ មិថុនា ២០១៦<br>ពាន់រៀល<br>(មិនបានត្រួតពិនិត្យ និងមិនបានធ្វើសវនកម្ម) |
| ចំណូលពីការជួល | ១.៣៨៦.៣០៨ | ៩០៦.០៨៦ |
| ចំណាយប្រតិបត្តិការផ្ទាល់ដែលកើតចេញពីការវិនិយោគទ្រព្យសម្បត្តិ ដែលបង្កើតឱ្យមានចំណូលពីការជួល | ១.៥៧២.៥០៧ | ១.២៥៣.៥៩៨ |

## ៩. ទ្រព្យសកម្មអរូបី

| | កម្មវិធី<br>ពាន់រៀល | សរុប<br>ពាន់រៀល |
|---|---|---|
| **នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦** | | |
| ថ្លៃដើម | ១២.៨៧២.៩២៣ | ១២.៨៧២.៩២៣ |
| រំលស់បង្គរ | (៣.៨៥២.៣៣១) | (៣.៨៥២.៣៣១) |
| តម្លៃចុះបញ្ជីសុទ្ធ | ៩.០២០.៥៩២ | ៩.០២០.៥៩២ |
| **ដំណាច់ការិយបរិច្ឆេទ៦ខែ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧ (បានត្រួតពិនិត្យ ប៉ុន្តែមិនបានធ្វើសវនកម្ម)** | | |
| តម្លៃចុះបញ្ជីសុទ្ធដើមគ្រា | ៩.០២០.៥៩២ | ៩.០២០.៥៩២ |
| ទិញបន្ថែម | ៥៩៥.០២៣ | ៥៩៥.០២៣ |
| រំលស់បង្គរ | (៥២៦.៤៧៧) | (៥២៦.៤៧៧) |
| តម្លៃចុះបញ្ជីសុទ្ធចុងគ្រា | ៩.០៨៩.១៣៨ | ៩.០៨៩.១៣៨ |
| **នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧** | | |
| ថ្លៃដើម | ១៣.៤៦៧.៩៤៦ | ១៣.៤៦៧.៩៤៦ |
| រំលស់បង្គរ | (៤.៣៧៨.៨០៨) | (៤.៣៧៨.៨០៨) |
| តម្លៃចុះបញ្ជីសុទ្ធ (បានត្រួតពិនិត្យ ប៉ុន្តែមិនបានធ្វើសវនកម្ម) | ៩.០៨៩.១៣៨ | ៩.០៨៩.១៣៨ |

**កំណត់សម្គាល់ព័ត៌មានហិរញ្ញវត្ថុសង្ខេប ( មិនបានធ្វើសវនកម្ម )**
**សម្រាប់ដំណាច់ការិយបរិច្ឆេទ៦ខែ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧**

## ១០. ឥណទានបុគ្គលិក

នៅថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ក.ស.ស បានអនុម័តផ្តល់ឥណទានគ្មានការប្រាក់ដល់បុគ្គលិក ក្នុងរយៈពេល៤ឆ្នាំ រួមទាំងបុគ្គលិកចូលនិវត្តន៍ ដើម្បីទិញភាគហ៊ុនអណ្តែត (floating share) នៅពេលចូល ក.ស.ស ប្រកាសលក់មូលបត្រសាធារណៈលើកដំបូង។ ឥណទាននេះមានចំនួនសរុប ១០.២៦៧ លានរៀល។

| | ៣០ មិថុនា ២០១៧<br>ពាន់រៀល<br>(បានត្រួតពិនិត្យ<br>ប៉ុន្តែមិនបានធ្វើសវនកម្ម) |
|---|---|
| តម្លៃយោង | ៧.៦៤៥.០៨០ |
| តម្លៃសមស្រប | ៧.៦៤៥.០៨០ |

តម្លៃសមស្របនៃឥណទានបុគ្គលិក គឺអាស្រ័យទៅតាមលំហូរសាច់ប្រាក់អប្បហារ ដោយប្រើអត្រាការប្រាក់មធ្យម ១៥,២៧% ក្នុងមួយឆ្នាំ។ គណៈគ្រប់គ្រងបានវាយតម្លៃថា អត្រាការប្រាក់ ១៥,២៧% គឺជាអត្រាសមស្រប ដោយសមមូលនឹងអត្រាដែលបុគ្គលិកអាចខ្ចីប្រាក់ពីធនាគារពាណិជ្ជនានាជាប្រាក់រៀល ក្នុងរយៈពេល៤ឆ្នាំ។

និយ័តកម្មតម្លៃសមស្របលើសមតុល្យឥណទាន ២.៦២២ លានរៀល ត្រូវបានកត់ត្រាជាទ្រព្យសកម្មផ្សេងៗ នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ និងដករំលស់ក្នុងរបាយការណ៍ចំណេញ-ខាត ក្នុងខ្ទង់ប្រាក់បៀវត្សរ៍ ប្រាក់ឈ្នួល និងចំណាយពាក់ព័ន្ធ ក្នុងរយៈពេល៤ឆ្នាំ ដោយសារតម្លៃសមស្របរបស់ឥណទាននេះ ត្រូវបានកាត់បន្ថយតាមរយៈអត្រាអនុគ្រោះ (គ្មានអត្រាការប្រាក់) ហើយអត្ថប្រយោជន៍ត្រូវបានផ្តល់ឱ្យបុគ្គលិក។

## ១១. សន្និធិ

| | ៣០ មិថុនា ២០១៧<br>ពាន់រៀល<br>(បានត្រួតពិនិត្យ<br>ប៉ុន្តែមិនបានធ្វើសវនកម្ម) | ៣១ ធ្នូ ២០១៦<br>ពាន់រៀល<br>(បានធ្វើសវនកម្ម) |
|---|---|---|
| សម្ភារប្រើប្រាស់ | ៦.៩៤៧.៤៥៩ | ៦.៥៤១.៨៧៣ |
| ប្រេងឥន្ធនៈ និងប្រេងម៉ាស៊ីនយានយន្ត | ៤៧៦.៧៧១ | ៦៦៨.៤៣៨ |
| សម្ភារងាយឆេះ | ៣៣៤.១៦០ | ៣២៨.៥៩៤ |
| សំវិធានធនសម្រាប់គ្រឿងបន្លាស់ (*) | (៧៤២.៩៩៤) | (៧៤២.៩៩៤) |
| | ៧.០១៥.៣៨៦ | ៦.៧៩៥.៩១១ |

(*) គណៈគ្រប់គ្រងធ្វើការវាយតម្លៃលើសន្និធិដែលដំណើរការយឺតទៅតាមពេលវេលាកំណត់ និងពិចារណាទៅលើតម្លៃសំវិធានធន ដែលនៅសល់មានភាពគ្រប់គ្រាន់ និងសមស្របនៅដំណាច់ឆ្នាំ។

**កំណត់សម្គាល់ព័ត៌មានហិរញ្ញវត្ថុសង្ខេប (មិនបានធ្វើសវនកម្ម)**
**សម្រាប់ដំណាច់ការិយបរិច្ឆេទ៦ខែ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧**

## ១២. គណនីអតិថិជនពាណិជ្ជកម្ម និងគណនីអតិថិជនផ្សេងៗ

| | ៣០ មិថុនា ២០១៧<br>ពាន់រៀល<br>(បានត្រួតពិនិត្យ ប៉ុន្តែមិនបានធ្វើសវនកម្ម) | ៣១ ធ្នូ ២០១៦<br>ពាន់រៀល<br>(បានធ្វើសវនកម្ម) |
|---|---|---|
| គណនីអតិថិជនពាណិជ្ជកម្ម | ១៩.៨០២.៥៤៤ | ១៧.៤៨៧.១១២ |
| គណនីអតិថិជនផ្សេងៗ៖ | | |
| បុរេប្រទានឱ្យក្រសួងសាធារណការ និងដឹកជញ្ជូន (*) | ៩.០០០.០០០ | ៥.០០០.០០០ |
| បុរេប្រទានផ្សេងៗ | ១.៥៦៧.៧៤៦ | ១.៥១៨.៨៨៦ |
| ឥណទានពន្ធកាត់ទុក | ៩២៧.០៨៩ | ៨៨៨.៣៧៦ |
| ចំណាយបង់មុន | ៤៨.៩៤៦ | ៤៨.៤០៧ |
| ផ្សេងៗ | ២.៨១៨.៥៤៥ | ២២២.៨១៣ |
| | ១៤.៣៦២.៣២៦ | ៧.៦៧៨.៤៨២ |
| ដក៖ សំវិធានធនបុរេប្រទានផ្សេងៗដែលមិនអាចប្រមូលមកវិញបាន | (៦១.០២៤) | (៦១.០២៤) |
| | ១៤.៣០១.៣០២ | ៧.៦១៧.៤៥៨ |
| | ៣៤.១០៣.៨៤៦ | ២៥.១០៤.៥៧០ |

(*) ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានចេញលិខិតមួយចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ បានស្នើឱ្យ ក.ស.ស ធ្វើបុរេប្រទានជាសាច់ប្រាក់ចំនួន ១៣.១០០លានរៀល ជូនក្រសួងសាធារណការ និងដឹកជញ្ជូន ដើម្បីជួសជុលកែលម្អ និងពង្រីកផ្នែកខ្លះនៅផ្លូវជាតិលេខ៤ ក្នុងខេត្តព្រះសីហនុ។ ក.ស.ស បានធ្វើបុរេប្រទានជាសាច់ប្រាក់ចំនួន ៥.០០០លានរៀល ជូនក្រសួងសាធារណការ និងដឹកជញ្ជូន ក្នុងខែធ្នូ ឆ្នាំ២០១៦ និង ៤.០០០លានរៀលទៀត ក្នុងខែមេសា ឆ្នាំ២០១៧។ ក្នុងលិខិតចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៧ ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក.ស.ស បានស្នើបង្វិលទឹកប្រាក់បុរេប្រទាន តាមរយៈជម្រើសពីរ (១) កាត់ពីដើមទុនរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ឬ (២) កាត់ពីភាគលាភត្រូវបែងចែកជូន ក្រសួងសាធារណការ និងដឹកជញ្ជូន នាពេលអនាគត។

អតិថិជនរបស់ ក.ស.ស គឺជាក្រុមហ៊ុន និងភ្នាក់ងារដឹកជញ្ជូនជាតិ និងអន្តរជាតិនានា។ សំវិធានធនសម្រាប់ការថយចុះតម្លៃ ត្រូវបានកត់ត្រាពេញលេញចំពោះចំនួនទឹកប្រាក់ដែលហួសកាលកំណត់សងលើសពីមួយឆ្នាំ។

ដោយសារគណនីអតិថិជនទាំងនេះមានរយៈពេលខ្លី តម្លៃសមស្របរបស់វាមានតម្លៃប្រហាក់ប្រហែលនឹងតម្លៃយោងដកសំវិធានធន។ ហានិភ័យឥណទានអតិបរមានាកាលបរិច្ឆេទរាយការណ៍ គឺជាតម្លៃយោងនៃគណនីអតិថិជននីមួយៗដូចបានរៀបរាប់ខាងលើ ដកនឹងសំវិធានធនបុរេប្រទានដែលមិនអាចប្រមូលបាន។

(ក) រាល់គណនីអតិថិជនទាំងអស់ មិនហួសកាលកំណត់សង និងមិនថយចុះតម្លៃ

(ខ) គណនីអតិថិជនផ្សេងៗ មិនហួសកាលកំណត់សង និងមិនថយចុះតម្លៃ លើកលែងតែបុរេប្រទានជាក់លាក់។ អាយុកាលរបស់វាមានរយៈពេលលើសពីមួយឆ្នាំ និងសំវិធានធនសម្រាប់បុរេប្រទានដែលមិនអាចប្រមូលមកវិញបានត្រូវបានកត់ត្រាគ្រប់ចំនួន។

**កំណត់សម្គាល់ព័ត៌មានហិរញ្ញវត្ថុសង្ខេប (មិនបានធ្វើសវនកម្ម)**
**សម្រាប់ដំណាច់ការិយបរិច្ឆេទ៦ខែ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧**

## ១៣. ប្រាក់បញ្ញើនៅធនាគាររយៈពេលខ្លី

ប្រាក់បញ្ញើនៅធនាគាររយៈពេលខ្លី គឺជាប្រាក់បញ្ញើមានកាលកំណត់ ដែលបានផ្ញើនៅគ្រឹះស្ថានហិរញ្ញវត្ថុនានា ក្នុងរយៈពេលពី៣ខែ ទៅ១២ខែ ហើយទទួលបានការប្រាក់ចន្លោះពី ៣,៥០% ទៅ ៦,០០% ក្នុងមួយឆ្នាំ (២០១៦ ៖ ចន្លោះពី ៣,៥០% ទៅ ៦,០០% ក្នុងមួយឆ្នាំ) ។

## ១៤. សាច់ប្រាក់ និងសាច់ប្រាក់សមមូល

| | ៣០ មិថុនា ២០១៧<br>ពាន់រៀល<br>(បានត្រួតពិនិត្យ<br>ប៉ុន្តែមិនបានធ្វើសវនកម្ម) | ៣១ ធ្នូ ២០១៦<br>ពាន់រៀល<br>(បានធ្វើសវនកម្ម) |
|---|---|---|
| សាច់ប្រាក់ក្នុងដៃ | ១.៩០៦.៣២៣ | ១.៩៨៦.២៨៦ |
| សាច់ប្រាក់នៅធនាគារ | | |
| គណនីចរន្ត | ១២៣.៥៧០.៤៦៣ | ៣២.៦៦៥.៣១៨ |
| | ១២៥.៤៧៦.៧៨៦ | ៣៤.៦៥១.៦០៤ |

សាច់ប្រាក់នៅធនាគារត្រូវបានតម្កល់នៅធនាគារពាណិជ្ជក្នុងស្រុក។ គណនីចរន្តមិនមានការប្រាក់ទេ។

សហជីពពាណិជ្ជរបស់បុគ្គលិក ក.ស.ស បានបើកគណនីធនាគារក្រោមឈ្មោះ ក.ស.ស។ គោលបំណងរបស់សហជីពពាណិជ្ជគឺដើម្បីរៃអង្គាសមូលនិធិពីបុគ្គលិកម្នាក់ៗ ដើម្បីឧបត្ថម្ភដល់បុគ្គលិកទាំងឡាយណា ដែលមានសេចក្តីត្រូវការចាំបាច់ផ្នែកហិរញ្ញវត្ថុ។ ក.ស.ស មិនបានកត់ត្រាចំនួនទឹកប្រាក់នេះនៅក្នុងបញ្ជីរបស់ខ្លួនទេ ដោយសារមូលនិធិនេះមិនមែនជាកម្មសិទ្ធិរបស់ ក.ស.ស ដោយគ្រាន់តែបានដើរតួនាទីជាអ្នកឈរឈ្មោះប៉ុណ្ណោះ។ គិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧ ទឹកប្រាក់ដែលស្ថិតនៅក្រោមឈ្មោះ ក.ស.ស ជាអ្នកឈរឈ្មោះ សម្រាប់សហជីពពាណិជ្ជមានចំនួន ១៥៥លានរៀល (៣១ ធ្នូ ២០១៦ ៖ ៣០១លានរៀល)។

## កំណត់សម្គាល់ព័ត៌មានហិរញ្ញវត្ថុសង្ខេប (មិនបានធ្វើសវនកម្ម)
## សម្រាប់ដំណាច់ការិយបរិច្ឆេទ៦ខែ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧

### ១៥. ដើមទុន

| | ចំនួនភាគហ៊ុន ប្រភេទ ខ (ខ្ទង់ពាន់) | ចំនួនភាគហ៊ុន ប្រភេទ ក (ខ្ទង់ពាន់) | ភាគហ៊ុន ប្រភេទ ខ ពាន់រៀល | បុព្វលាភ ភាគហ៊ុន ពាន់រៀល | ភាគហ៊ុន ប្រភេទ ក ពាន់រៀល | ដើមទុន ពាន់រៀល | សរុប ពាន់រៀល |
|---|---|---|---|---|---|---|---|
| *ដំណាច់ការិយបរិច្ឆេទ៦ខែ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៦* | | | | | | | |
| *(មិនបានត្រួតពិនិត្យ និងមិនបានធ្វើសនវកម្ម)* | | | | | | | |
| នៅថ្ងៃទី ០១ ខែមករា ឆ្នាំ២០១៦ | - | - | - | - | - | ៤២៨.៨៥៩.៨៣៦ | ៤២៨.៨៥៩.៨៣៦ |
| *នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៦* | | | | | | | |
| *(មិនបានត្រួតពិនិត្យ និងមិនបានធ្វើសនវកម្ម)* | - | - | - | - | - | ៤២៨.៨៥៩.៨៣៦ | ៤២៨.៨៥៩.៨៣៦ |
| *ដំណាច់ការិយបរិច្ឆេទ៦ខែ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧* | | | | | | | |
| *(បានត្រួតពិនិត្យ ប៉ុន្តែមិនបានធ្វើសនវកម្ម)* | | | | | | | |
| នៅថ្ងៃទី ០១ ខែមករា ឆ្នាំ២០១៧ | - | - | - | - | - | ៤២៨.៨៥៩.៨៣៦ | ៤២៨.៨៥៩.៨៣៦ |
| ការផ្ទេរដើមទុន ទៅជាភាគហ៊ុន (ក) | ៦៤.៣២៩ | ៣៦៤.៥៣១ | ៦៤.៣២៨.៩៧៥ | - | ៣៦៤.៥៣០.៨៦១ | (៤២៨.៨៥៩.៨៣៦) | - |
| សាច់ប្រាក់ពីការចេញផ្សាយភាគហ៊ុន (ខ) | ២១.៤៤៣ | - | ២១.៤៤២.៩៩២ | ៨១.៨៩៦.០៧៨ | - | - | ១០៣.៣៣៩.០៧០ |
| *នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧* | | | | | | | |
| *(បានត្រួតពិនិត្យ ប៉ុន្តែមិនបានធ្វើសនវកម្ម)* | ៨៥.៧៧២ | ៣៦៤.៥៣១ | ៨៥.៧៧១.៩៦៧ | ៨១.៨៩៦.០៧៨ | ៣៦៤.៥៣០.៨៦១ | - | ៥៣២.១៩៨.៩០៦ |

**កំណត់សម្គាល់ព័ត៌មានហិរញ្ញវត្ថុសង្ខេប ( មិនបានធ្វើសវនកម្ម )**
**សម្រាប់ដំណាច់ការិយបរិច្ឆេទ៦ខែ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧**

## ១៥. ដើមទុន (ត)

(ក) នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៦ ក្រុមប្រឹក្សាភិបាលបានអនុម័តបំបែកដើមទុនដែលមានស្រាប់ចំនួន ៤២៨.៨៥៩.៨៣៦.០០០ រៀល ទៅជាភាគហ៊ុនប្រភេទ ក ចំនួន ៣៦៤.៥៣១.៨៦១ ភាគហ៊ុន និងភាគហ៊ុនប្រភេទ ខ ចំនួន ៦៤.៣២៨.៩៧៥ ភាគហ៊ុន ដែលមានតម្លៃចារិក ១.០០០ រៀល ក្នុងមួយភាគហ៊ុន។ ភាគហ៊ុនប្រភេទ ក ត្រូវបាន គ្រប់គ្រងដោយរាជរដ្ឋាភិបាលកម្ពុជា ដែលមានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាតំណាង ហើយមិនមានសិទ្ធិ បោះឆ្នោត ទេ លើកលែងតែក្នុង លក្ខខណ្ឌមួយចំនួន ដូចបានលម្អិតក្នុងមាត្រា ៩ នៃលក្ខន្តិកៈរបស់ ក.ស.ស ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៧។

(ខ) នៅថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៧ ក.ស.ស បានចុះបញ្ជីដោយជោគជ័យក្នុងទីផ្សារមូលបត្រកម្ពុជា។ ភាគហ៊ុនប្រភេទ ខ មានចំនួនសរុប ៨៥.៧៧១.៩៦៧ ភាគហ៊ុន ដែលមានតម្លៃចារិក ១.០០០ រៀល ក្នុងមួយភាគហ៊ុន ហើយតម្លៃ ចេញផ្សាយមានចំនួន ៥.០៤០រៀល ក្នុងមួយភាគហ៊ុន។ ថ្លៃដើមក្នុងការចេញផ្សាយភាគហ៊ុនថ្មីចំនួន ២១.៤៤២.៩៩២ ភាគហ៊ុន មានចំនួន ៦.៥៩៧លានរៀល ត្រូវបានកាត់កងជាមួយនឹងបុព្វលាភភាគហ៊ុន។ ភាគហ៊ុនប្រភេទ ខ ដែល បានចេញផ្សាយទាំងអស់ ត្រូវបានទូទាត់រួចរាល់ទាំងស្រុង។

| **ភាគហ៊ុនិក** | **ចំនួនភាគហ៊ុន** |
|---|---|
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ៦៤.៣២៨.៩៧៥ |
| Japan International Cooperation Agency (JICA) | ១១.៥៧៩.២១៦ |
| វិនិយោគិនផ្សេងៗ | ៩.៨៦៣.៧៧៦ |
| | ៨៥.៧៧១.៩៦៧ |

## ១៦. ទុនបម្រុងផ្សេងៗ

មាត្រា១៣នៃលក្ខន្តិកៈរបស់ ក.ស.ស ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០១ បានចែងថា ប្រាក់ចំណេញរបស់ ក.ស.ស បន្ទាប់ពីកាត់កងការខាតយោង (ប្រសិនបើមាន) ត្រូវបានបែងចែកទៅក្នុងទុនបម្រុងទូទៅ និងទុនបម្រុងតាមច្បាប់។ ការបែងចែក នេះ ត្រូវមានការអនុម័តដោយក្រុមប្រឹក្សាភិបាល មុនពេលកត់ត្រា។

## កំណត់សម្គាល់ព័ត៌មានហិរញ្ញវត្ថុសង្ខេប (មិនបានធ្វើសវនកម្ម)
## សម្រាប់ដំណាច់ការិយបរិច្ឆេទ៦ខែ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧

### ១៧. ប្រាក់កម្ចី

| | ៣០ មិថុនា ២០១៧<br>ពាន់រៀល<br>(បានត្រួតពិនិត្យ ប៉ុន្តែមិនបានធ្វើសវនកម្ម) | ៣១ ធ្នូ ២០១៦<br>ពាន់រៀល<br>(បានធ្វើសវនកម្ម) |
|---|---|---|
| ប្រាក់កម្ចីពី៖ | | |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ – (JICA) – ឥណទានលេខ CP-P3 | ៩០.០៦៣.១៣២ | ៨៩.០៥៥.៥៥៦ |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ – (JBIC) – ឥណទានលេខ CP-P4 | ១៣២.៣០៧.៨៣៩ | ១៣៤.៥២០.២៩៩ |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ – (JBIC) – ឥណទានលេខ CP-P6 | ៨.៩១១.០៤៩ | ៨.៧០៩.១២១ |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ – (JBIC) – ឥណទានលេខ CP-P8 | ១២៩.២៥២.៤៥៧ | ១២២.៩៦៣.៨៦០ |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ – (JBIC) – ឥណទានលេខ CP-P10 | ១៤៨.៨០៨.២៥១ | ១២៤.៥៣០.២៧០ |
| | ៥០៩.៣៤២.៧២៨ | ៤៧៩.៧៧៩.១០៦ |

កាលកំណត់របស់ប្រាក់កម្ចីទាំងនេះមានដូចខាងក្រោម៖

| | ៣០ មិថុនា ២០១៧<br>ពាន់រៀល<br>(បានត្រួតពិនិត្យ ប៉ុន្តែមិនបានធ្វើសវនកម្ម) | ៣១ ធ្នូ ២០១៦<br>ពាន់រៀល<br>(បានធ្វើសវនកម្ម) |
|---|---|---|
| **ប្រាក់កម្ចីរយៈពេលខ្លី** | | |
| ផុតកំណត់ក្នុងរយៈពេលមួយឆ្នាំ | ២០.៧៨៩.៥១២ | ១៦.៥៤៣.៧៣៥ |
| **ប្រាក់កម្ចីរយៈពេលវែង** | | |
| ផុតកំណត់ក្នុងរយៈពេលមួយឆ្នាំទៅពីរឆ្នាំ | ២១.០៤៣.៣៨១ | ២០.២៩៤.៨៧៩ |
| ផុតកំណត់ក្នុងរយៈពេលពីរឆ្នាំទៅប្រាំឆ្នាំ | ៨២.២៨៧.២៥៩ | ៧៦.០៧០.៣២៨ |
| ផុតកំណត់ក្នុងរយៈពេលប្រាំឆ្នាំ | ៣៨៥.២២២.៥៧៦ | ៣៦៦.៨៧០.១៦៥ |
| | ៤៨៨.៥៥៣.២១៦ | ៤៦៣.២៣៥.៣៧២ |
| | ៥០៩.៣៤២.៧២៨ | ៤៧៩.៧៧៩.១០៧ |

តម្លៃយោង និងតម្លៃសមស្របរបស់ប្រាក់កម្ចីរយៈពេលវែង មានដូចខាងក្រោម៖

| | ៣០ មិថុនា ២០១៧<br>ពាន់រៀល<br>(បានត្រួតពិនិត្យ ប៉ុន្តែមិនបានធ្វើសវនកម្ម) | ៣១ ធ្នូ ២០១៦<br>ពាន់រៀល<br>(បានធ្វើសវនកម្ម) |
|---|---|---|
| តម្លៃយោង | ៥០៩.៣៤២.៧២៨ | ៤៧៩.៧៧៩.១០៦ |
| តម្លៃសមស្រប | ៤៩៩.៥២៣.៧១៥ | ៤៧០.៩៧៧.៤៥០ |

**កំណត់សម្គាល់ព័ត៌មានហិរញ្ញវត្ថុសង្ខេប ( មិនបានធ្វើសវនកម្ម )**
**សម្រាប់ដំណាច់ការិយបរិច្ឆេទ៦ខែ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧**

## ១៧. ប្រាក់កម្ចី ( ត )

តម្លៃសមស្របរបស់ប្រាក់កម្ចី គឺអាស្រ័យទៅលើលំហូរសាច់ប្រាក់អប្បហារ ដោយប្រើអត្រាប្រាក់កម្ចី។ វាត្រូវបានចាត់ថ្នាក់ជាតម្លៃសមស្របកម្រិតបីក្នុងលំដាប់ថ្នាក់តម្លៃសមស្រប ដោយសារការប្រើប្រាស់ធាតុចូលដែលមិនអាចអង្កេតបាន។

ប្រាក់កម្ចីជារូបិយប័ណ្ណផ្សេងៗក្រៅពីរូបិយប័ណ្ណគោល មានដូចខាងក្រោម៖

| | **៣០ មិថុនា ២០១៧ ពាន់រៀល** | **៣១ ធ្នូ ២០១៦ ពាន់រៀល** |
|---|---|---|
| | (បានត្រួតពិនិត្យ ប៉ុន្តែមិនបានធ្វើសវនកម្ម) | (បានធ្វើសវនកម្ម) |
| ប្រាក់យ៉េន | ៣៧៧.០៣៤.៨៨៩ | ៣៤៥.២៥៨.៨០៧ |
| ប្រាក់ដុល្លារអាមេរិក | ១៣២.៣០៧.៨៣៩ | ១៣៤.៥២០.២៩៩ |
| | ៥០៩.៣៤២.៧២៨ | ៤៧៩.៧៧៩.១០៦ |

ប្រាក់កម្ចីទាំងអស់មានរយៈពេល៣០ឆ្នាំ ហើយអត្រាការប្រាក់ប្រចាំឆ្នាំនៃប្រាក់កម្ចីនីមួយៗ មានដូចខាងក្រោម៖

| | **៣០ មិថុនា ២០១៧** | **៣១ ធ្នូ ២០១៦** |
|---|---|---|
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ – (JICA) – ឥណទានលេខ CP-P3 | ៣,00% | ៣,00% |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ – (JBIC) – ឥណទានលេខ CP-P4 | ៣,៧0% | ៣,៧0% |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ – (JBIC) – ឥណទានលេខ CP-P6 | ៣,00% | ៣,00% |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ – (JBIC) – ឥណទានលេខ CP-P8 | ២,៥0% | ២,៥0% |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ – (JBIC) – ឥណទានលេខ CP-P10 | ២,៥0% | ២,៥0% |

## ១៨. កាតព្វកិច្ចអត្ថប្រយោជន៍សោធននិវត្តន៍

ចំនួនទឹកប្រាក់ដែលបានកត់ត្រានៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ មានដូចខាងក្រោម៖

| | **៣០ មិថុនា ២០១៧ ពាន់រៀល** | **៣១ ធ្នូ ២០១៦ ពាន់រៀល** |
|---|---|---|
| | (បានត្រួតពិនិត្យ ប៉ុន្តែមិនបានធ្វើសវនកម្ម) | (បានធ្វើសវនកម្ម) |
| តម្លៃបច្ចុប្បន្ននៃកាតព្វកិច្ចអត្ថប្រយោជន៍ដែលបានកំណត់ | ៤០.៥២៥.១៣៩ | ៤០.៣០១.៤១១ |
| ស្ថានភាពអធន (Unfunded status) | ៤០.៥២៥.១៣៩ | ៤០.៣០១.៤១១ |
| បំណុលសុទ្ធដែលបានកត់ត្រាក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ | ៤០.៥២៥.១៣៩ | ៤០.៣០១.៤១១ |

## ១៨. ភាតព្វកិច្ចអត្ថប្រយោជន៍សោធននិវត្តន៍ (ត)

បម្រែបម្រួលកាតព្វកិច្ចអត្ថប្រយោជន៍ដែលបានកំណត់ក្នុងការិយបរិច្ឆេទនេះ មានដូចខាងក្រោម៖

| | **៣០ មិថុនា ២០១៧**<br>**ពាន់រៀល**<br>(បានត្រួតពិនិត្យ<br>ប៉ុន្តែមិនបានធ្វើសវនកម្ម) | **៣០ មិថុនា ២០១៦**<br>**ពាន់រៀល**<br>(មិនបានត្រួតពិនិត្យ<br>និងមិនបានធ្វើសវនកម្ម) |
|---|---:|---:|
| សមតុល្យដើមគ្រា | ៤០.៣០១.៤១១ | ៣៩.៤៩៦.៧៨៨ |
| ចំណាយលើសេវាបច្ចុប្បន្ន | ៥៧៤.០០០ | ៥៩៧.៥០០ |
| ចំណាយការប្រាក់ | ១.៥០៣.០០០ | ១.៤៣៥.០០០ |
| អត្ថប្រយោជន៍បានបង់ | (១.៨៥៣.២៧២) | (១.៤៧០.៣០៣) |
| សមតុល្យចុងគ្រា | ៤០.៥២៥.១៣៩ | ៤០.០៥៨.៩៨៥ |

ទឹកប្រាក់ដែលបានកត់ត្រាក្នុងខ្ទង់ចំណាយប្រាក់បៀវត្សរ៍ និងចំណាយពាក់ព័ន្ធ ក្នុងរបាយការណ៍ចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗក្នុងការិយបរិច្ឆេទ មានដូចខាងក្រោម៖

| | **ដំណាច់ការិយបរិច្ឆេទ៦ខែ** | |
|---|---:|---:|
| | **៣០ មិថុនា ២០១៧**<br>**ពាន់រៀល**<br>(បានត្រួតពិនិត្យ<br>ប៉ុន្តែមិនបានធ្វើសវនកម្ម) | **៣០ មិថុនា ២០១៦**<br>**ពាន់រៀល**<br>(មិនបានត្រួតពិនិត្យ<br>និងមិនបានធ្វើសវនកម្ម) |
| ចំណាយលើសេវាកម្មបច្ចុប្បន្ន | ៥៧៤.០០០ | ៥៩៧.៥០០ |
| ចំណាយការប្រាក់ | ១.៥០៣.០០០ | ១.៤៣៥.០០០ |
| | ២.០៧៧.០០០ | ២.០៣២.៥០០ |

ការសន្មតការគណនាហានិភ័យសំខាន់ៗ មានដូចខាងក្រោម៖

| | **២០១៧** | **២០១៦** |
|---|---:|---:|
| មធ្យមភាគនៃការរំពឹងទុកនៃចំនួនឆ្នាំបម្រើការងារ | ២០ | ២០ |
| អត្រាអប្បហារ | ៧% | ៧% |
| អត្រាកំណើនប្រាក់បៀវត្សរ៍ | ៥% | ៥% |
| អត្រាមរណៈ | | |

## ១៨. ភាគព្វកិច្ចអត្ថប្រយោជន៍សោធននិវត្តន៍ (ត)

**អត្រាមរណៈ**

ដោយសារមិនមានអត្រាមរណៈត្រូវបានចេញផ្សាយនៅក្នុងប្រទេសកម្ពុជា ក.ស.ស បានប្រើប្រាស់តារាងអត្រាមរណៈរបស់ប្រទេសថៃឆ្នាំ២០០៨ ហើយបានកែសម្រួលដើម្បីឱ្យសមស្របទៅនឹងអាយុកាលរំពឹងទុករបស់ប្រជាជនកម្ពុជា។ តារាងអត្រាមរណៈរបស់ប្រទេសថៃឆ្នាំ២០០៨ គឺជាតារាងអត្រាមរណៈដែលបានចេញផ្សាយចុងក្រោយគេបំផុតនៅក្នុងប្រទេសថៃ ហើយវានៅរក្សាអត្រាដដែល គិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧។

## ១៩. ចំណូលពន្យារ

ក.ស.ស បានជួលផ្នែកខ្លះនៃដីរបស់ខ្លួនក្នុងតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ ក្រោមកិច្ចសន្យាភតិសន្យាប្រតិបត្តិ រយៈពេល៥០ឆ្នាំ។ ចំណាយបង់មុនត្រូវបានកត់ត្រាក្នុងខ្ទង់ឥណទានក្នុងរបាយការណ៍ចំណេញ-ខាត តាមមូលដ្ឋានថេរ អាស្រ័យទៅតាមរយៈពេលនៃភតិសន្យា។

| | **៣០ មិថុនា ២០១៧**<br>**ពាន់រៀល**<br>(បានត្រួតពិនិត្យ<br>ប៉ុន្តែមិនបានធ្វើសវនកម្ម) |
|---|---:|
| សមតុល្យដើមគ្រា | ៦.០៦១.៥៥៦ |
| បន្ថែម | ២៣២.១០៩ |
| កត់ត្រាក្នុងខ្ទង់ឥណទានក្នុងរបាយការណ៍ចំណេញ-ខាត | (១៤៤.២៤៤) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | ៧៣.០២៩ |
| សមតុល្យចុងគ្រា | ៦.២២២.៤៥០ |

| | **៣០ មិថុនា ២០១៧**<br>**ពាន់រៀល**<br>(បានត្រួតពិនិត្យ<br>ប៉ុន្តែមិនបានធ្វើសវនកម្ម) |
|---|---:|
| រយៈពេលខ្លី | ១៣២.១៦៥ |
| រយៈពេលវែង | ៦.០៩០.២៨៥ |
| | ៦.២២២.៤៥០ |

**កំណត់សម្គាល់ព័ត៌មានហិរញ្ញវត្ថុសង្ខេប ( មិនបានធ្វើសវនកម្ម )**
**សម្រាប់ដំណាច់ការិយបរិច្ឆេទ៦ខែ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧**

## ២០. គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីអ្នកផ្គត់ផ្គង់ផ្សេងៗ

| | ៣០ មិថុនា ២០១៧ ពាន់រៀល (បានត្រួតពិនិត្យ ប៉ុន្តែមិនបានធ្វើសវនកម្ម) | ៣១ ធ្នូ ២០១៦ ពាន់រៀល (បានធ្វើសវនកម្ម) |
|---|---|---|
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម | ៦.០៨០.៧៥០ | ៥.៨៦២.៧៣៩ |
| | | |
| ប្រាក់រង្វាន់បង្គរ | ៧.០៦៤.០៦៧ | ៧.០៦៤.០៦៧ |
| អាករលើតម្លៃបន្ថែមត្រូវបង់ | ១.១៤១.៣១៤ | ១.០៨៧.២៥៧ |
| ប្រាក់កក់របស់អតិថិជន (*) | ៥៧០.៤៥៤ | ៩៣៩.២៤៣ |
| ពន្ធលើប្រាក់បៀវត្សរ៍ត្រូវបង់ | ២៤២.៤៤៤ | ២៨៥.៥២១ |
| បំណុលផ្សេងៗ | ១.១១១.៩៣៥ | ៤៧៥.០៦០ |
| | ១០.១៣០.២១៤ | ៩.៨៥១.១៤៨ |
| | | |
| | ១៦.២១០.៩៦៤ | ១៥.៧១៣.៨៨៧ |

(*) ប្រាក់កក់របស់អតិថិជនរួមមានសាច់ប្រាក់ដែលប្រមូលពីក្រុមហ៊ុនដឹកជញ្ជូនតាមនាវា សម្រាប់ការធានា និង ចំណាយបង់មុនលើកម្រៃប្រតិបត្តិការ។ ប្រាក់កក់ត្រូវបានបង្វិលឱ្យអតិថិជនវិញ នៅពេលដែលអតិថិជនបញ្ចប់ទំនាក់ទំនងអាជីវកម្មរបស់ខ្លួនជាមួយ ក.ស.ស ។

## ២១. ចំណូល

| | ដំណាច់ការិយបរិច្ឆេទ៦ខែ | |
|---|---|---|
| | ៣០ មិថុនា ២០១៧ ពាន់រៀល (បានត្រួតពិនិត្យ ប៉ុន្តែមិនបានធ្វើសវនកម្ម) | ៣០ មិថុនា ២០១៦ ពាន់រៀល (មិនបានត្រួតពិនិត្យ និងមិនបានធ្វើសវនកម្ម) |
| ចំណូលបានពីកំពង់ផែ | ១០២.៣៨២.២៩៥ | ១០០.៤៩៧.៥១០ |
| ចំណូលបានមកពីការជួលតំបន់សេដ្ឋកិច្ចពិសេស | ១.៣៨៦.៣០៨ | ៩០៦.០៨៦ |
| ចំណូលផ្សេងៗ | ៣៩២.៥៥១ | ៦៦៥.២៧០ |
| | ១០៤.១៦១.១៥៤ | ១០២.០៦៨.៨៦៦ |

**កំណត់សម្គាល់ព័ត៌មានហិរញ្ញវត្ថុសង្ខេប ( មិនបានធ្វើសវនកម្ម )**
**សម្រាប់ដំណាច់ការិយបរិច្ឆេទ៦ខែ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧**

## ២២. សម្ភារប្រើប្រាស់

| | ដំណាច់ការិយបរិច្ឆេទ៦ខែ | |
|---|---|---|
| | **៣០ មិថុនា ២០១៧**<br>**ពាន់រៀល** | **៣០ មិថុនា ២០១៦**<br>**ពាន់រៀល** |
| | (បានត្រួតពិនិត្យ<br>ប៉ុន្តែមិនបានធ្វើសវនកម្ម) | (មិនបានត្រួតពិនិត្យ<br>និងមិនបានធ្វើសវនកម្ម) |
| ចំណាយលើសម្ភារងាយឆេះ | ១៤.៦៣៥.១៩៣ | ១០.៣៧១.៦៥០ |
| គ្រឿងបន្លាស់ | ៤.៩៤៦.៩៧៨ | ៥.៩២១.៩១៥ |
| សម្ភារឃ្លាំង | ៣.១៦៩.០១៣ | ៤៣១.៩២៦ |
| ប្រេងឥន្ធនៈយានយន្ត | ១.២៤៧.៤៤១ | ១.២៤៤.៩៩១ |
| សម្ភារផ្គត់ផ្គង់ការិយាល័យ | ៨៨៨.៤៤១ | ១.១៩៨.៦៩៦ |
| សម្ភារប្រើប្រាស់ផ្សេងៗ | ១៧៦.៣០៤ | ៨៣.២៦០ |
| | ២៥.០៦៣.៣៧០ | ១៩.២៥២.៤៣៨ |

## ២៣. ចំណាយលើប្រាក់បៀវត្សរ៍ ប្រាក់ឈ្នួល និងចំណាយពាក់ព័ន្ធ

| | ដំណាច់ការិយបរិច្ឆេទ៦ខែ | |
|---|---|---|
| | **៣០ មិថុនា ២០១៧**<br>**ពាន់រៀល** | **៣០ មិថុនា ២០១៦**<br>**ពាន់រៀល** |
| | (បានត្រួតពិនិត្យ<br>ប៉ុន្តែមិនបានធ្វើសវនកម្ម) | (មិនបានត្រួតពិនិត្យ<br>និងមិនបានធ្វើសវនកម្ម) |
| ប្រាក់បៀវត្សរ៍បុគ្គលិក | ២០.៥៤៩.៨៩០ | ២០.៥១៣.៣៩៦ |
| ចំណាយអត្ថប្រយោជន៍សោធននិវត្តន៍ (កំណត់សម្គាល់ ១៨) | ២.០៧៧.០០០ | ២.០៣២.៥០០ |
| លាភការរបស់ក្រុមប្រឹក្សាភិបាល | ៨២៤.៩៥៥ | ៣១៦.៥២០ |
| ចំណាយសន្តិសុខសង្គមផ្សេងៗ | ១៤១.៥០៩ | ១២៧.៩៥៦ |
| ប្រាក់ឈ្នួលសម្រាប់អ្នកម៉ៅការ | ៧០.១០០ | ៨០.៥៦៤ |
| ប្រាក់រង្វាន់ | - | ១០.៦៣០ |
| ចំណាយផ្សេងៗពាក់ព័ន្ធនឹងបុគ្គលិក | ១.០២៧.៩៣១ | ១.១៩៨.០៨១ |
| | ២៤.៦៩១.៣៨៥ | ២៤.២៧៩.៦៤៧ |

**កំណត់សម្គាល់ព័ត៌មានហិរញ្ញវត្ថុសង្ខេប ( មិនបានធ្វើសវនកម្ម )**
**សម្រាប់ដំណាច់ការិយបរិច្ឆេទ៦ខែ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧**

## ២៤. ចំណាយរំលស់ទ្រព្យសម្បត្តិ និងបរិក្ខារ និងរំលស់ទ្រព្យសកម្មអរូបី

| | ដំណាច់ការិយបរិច្ឆេទ៦ខែ | |
|---|---|---|
| | **៣០ មិថុនា ២០១៧** | **៣០ មិថុនា ២០១៦** |
| | **ពាន់រៀល** | **ពាន់រៀល** |
| | (បានត្រួតពិនិត្យ ប៉ុន្តែមិនបានធ្វើសវនកម្ម) | (មិនបានត្រួតពិនិត្យ និងមិនបានធ្វើសវនកម្ម) |
| ទ្រព្យសម្បត្តិ និងបរិក្ខារ (កំណត់សម្គាល់ ៧) | ៧.៩៩៣.១៩៨ | ៧.៥១២.០៧៨ |
| ទ្រព្យសម្បត្តិវិនិយោគ (កំណត់សម្គាល់ ៨) | ៣.០៣១.៥១៣ | ៣.០២៩.៩៤២ |
| ទ្រព្យសកម្មអរូបី (កំណត់សម្គាល់ ៩) | ៥២៦.៤៧៧ | ២២០.៨៥២ |
| | ១១.៥៥១.១៨៨ | ១០.៧៦២.៨៧២ |

## ២៥. ចំណាយផ្សេងៗ

| | ដំណាច់ការិយបរិច្ឆេទ៦ខែ | |
|---|---|---|
| | **៣០ មិថុនា ២០១៧** | **៣០ មិថុនា ២០១៦** |
| | **ពាន់រៀល** | **ពាន់រៀល** |
| | (បានត្រួតពិនិត្យ ប៉ុន្តែមិនបានធ្វើសវនកម្ម) | (មិនបានត្រួតពិនិត្យ និងមិនបានធ្វើសវនកម្ម) |
| វិភាគទាន និងការធ្វើអំណោយ | ២.៨២៤.៩៩២ | ២.៩៥២.១៦៦ |
| ចំណាយរដ្ឋបាល | ២.២៧០.៩២៤ | ២.០៥៤.៣៥២ |
| ចំណាយប្រតិបត្តិការតំបន់សេដ្ឋកិច្ចពិសេស | ១.៥៧២.៥០៧ | ១.២៥៣.៥៩៨ |
| ការទទួលភ្ញៀវ និងបដិសណ្ឋារកិច្ច | ១.៥៣០.៦៨៧ | ១.៥០២.៧៥២ |
| ការបណ្តុះបណ្តាល និងសិក្ខាសាលា | ៥៦៧.៧៤៣ | ៤៤៤.៨៣៩ |
| បេសកកម្ម | ៥៥១.៨១៧ | ៤០៦.៤៣៩ |
| ការបោះពុម្ព | ៤២៤.៨៦៦ | ៣៥០.២៩១ |
| សេវាប្រៃសណីយ៍ | ៣៦៥.១១៩ | ៤៩៧.៨១០ |
| កម្រៃផ្នែកសេវាវិជ្ជាជីវៈ និងចំណាយពាក់ព័ន្ធ | ២៩៦.៧២២ | ១៧២.៧៧៦ |
| ទឹកភ្លើង | ៩២.២៨៥ | ៩៣.៣២៥ |
| ការជួលឧបករណ៍ | ៨៧.៩០៩ | ៥៥.៩៩២ |
| សម្ភារថែទាំសុខភាព | ៨៤.០៥៣ | ៨៥.៧៦៣ |
| ពន្ធដារ | ១០.០០០ | ១.០៦៨.០០៦ |
| ចំណាយផ្សេងៗ | ៥២.៤៦៦ | ១៥.៦៩៩ |
| | ១០.៧៣២.០៩០ | ១០.៩៥៣.៨០៨ |

**កំណត់សម្គាល់ព័ត៌មានហិរញ្ញវត្ថុសង្ខេប (មិនបានធ្វើសវនកម្ម)**
**សម្រាប់ដំណាច់ការិយបរិច្ឆេទ៦ខែ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧**

## ២៦. ចំណេញ/(ខាត)ផ្សេងៗ - សុទ្ធ

| | ដំណាច់ការិយបរិច្ឆេទ៦ខែ | |
|---|---|---|
| | **៣០ មិថុនា ២០១៧** | **៣០ មិថុនា ២០១៦** |
| | **ពាន់រៀល** | **ពាន់រៀល** |
| | (បានត្រួតពិនិត្យ ប៉ុន្តែមិនបានធ្វើសវនកម្ម) | (មិនបានត្រួតពិនិត្យ និងមិនបានធ្វើសវនកម្ម) |
| ចំណេញពីការប្តូររូបិយប័ណ្ណ | (១.០៧០.៣៤៥) | (១.០៧២.៥៣២) |
| ខាតពីការប្តូររូបិយប័ណ្ណ | ៨១០.៣០៦ | ៩៥១.៤២៧ |
| ចំណេញពីការប្តូររូបិយប័ណ្ណ - សុទ្ធ | (២៦០.០៣៩) | (១២១.១០៥) |

## ២៧. ចំណាយការប្រាក់ - សុទ្ធ

| | ដំណាច់ការិយបរិច្ឆេទ៦ខែ | |
|---|---|---|
| | **៣០ មិថុនា ២០១៧** | **៣០ មិថុនា ២០១៦** |
| | **ពាន់រៀល** | **ពាន់រៀល** |
| | (បានត្រួតពិនិត្យ ប៉ុន្តែមិនបានធ្វើសវនកម្ម) | (មិនបានត្រួតពិនិត្យ និងមិនបានធ្វើសវនកម្ម) |
| ចំណូលការប្រាក់៖ | | |
| ចំណូលការប្រាក់ពីប្រាក់បញ្ញើនៅធនាគារ (ក) | ១០៥.៦៥៧ | ២៥.៩៦៥ |
| | ១០៥.៦៥៧ | ២៥.៩៦៥ |
| ចំណាយការប្រាក់៖ | | |
| ខាតសុទ្ធពីការប្តូររូបិយប័ណ្ណលើប្រាក់កម្ចី (គ) | (១៩.៣៧៥.៧០២) | (៥៨.៧៣១.៩៣៤) |
| ចំណាយការប្រាក់លើប្រាក់កម្ចី (ខ) | (៥.៥២៩.១៧២) | (៦.១៣៥.៤៣៨) |
| | (២៤.៩០៤.៨៧៤) | (៦៤.៨៦៧.៣៧២) |
| ចំណាយការប្រាក់ - សុទ្ធ | (២៤.៧៩៩.២១៧) | (៦៤.៨៤១.៤០៧) |

(ក) ចំណូលការប្រាក់គឺជាចំណូលពីគណនីប្រាក់បញ្ញើសន្សំ និងប្រាក់បញ្ញើផ្សេងៗដែលផ្ញើនៅក្នុងធនាគារក្នុងស្រុក ក្នុងអំឡុងការិយបរិច្ឆេទ។

(ខ) ចំណាយការប្រាក់គឺជាការប្រាក់លើប្រាក់កម្ចី ដែលទទួលបានពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈការផ្តល់មូលនិធិដោយ JICA និង JBIC។

**កំណត់សម្គាល់ព័ត៌មានហិរញ្ញវត្ថុសង្ខេប ( មិនបានធ្វើសវនកម្ម )**
**សម្រាប់ដំណាច់ការិយបរិច្ឆេទ៦ខែ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧**

## ២៧. ចំណាយការប្រាក់ - សុទ្ធ ( ត )

(គ) ក.ស.ស មានប្រាក់កម្ចីជាប្រាក់យ៉េនជប៉ុន និងជាប្រាក់ដុល្លារអាមេរិក (កំណត់សម្គាល់១៦)។ ដោយសារតែការធ្លាក់ចុះប្រាក់រៀលធៀបនឹងប្រាក់យ៉េនជប៉ុន វាបណ្តាលឱ្យមានការខាតពីការប្តូររូបិយប័ណ្ណជាសារវន្ត លើប្រាក់កម្ចីជាប្រាក់យ៉េន។ អត្រាប្តូរដែលត្រូវបានផ្សព្វផ្សាយដោយធនាគារជាតិ នៃ កម្ពុជា នាដំណាច់ការិយបរិច្ឆេទរាយការណ៍ មានដូចខាងក្រោម៖

| | **៣០ មិថុនា ២០១៧** | **៣១ ធ្នូ ២០១៦** | **៣០ មិថុនា ២០១៦** | **៣១ ធ្នូ ២០១៥** |
|---|---|---|---|---|
| ប្រាក់យ៉េន/ប្រាក់រៀល | ៣៦,៦៣ | ៣៤,៨៥ | ៣០,៣៦ | ៣៣,៧៩ |
| ប្រាក់ដុល្លារអាមេរិក/ប្រាក់រៀល | ៤.០៨៦ | ៤.០៣៧ | ៤.០៨៩ | ៤.០៥០ |

## ២៨. ចំណាយពន្ធលើប្រាក់ចំណេញ

### ( ក ) ចំណាយពន្ធលើប្រាក់ចំណេញ

| | **ដំណាច់ការិយបរិច្ឆេទ៦ខែ** | |
|---|---|---|
| | **៣០ មិថុនា ២០១៧ ពាន់រៀល** | **៣០ មិថុនា ២០១៦ ពាន់រៀល** |
| | (បានត្រួតពិនិត្យ ប៉ុន្តែមិនបានធ្វើសវនកម្ម) | (មិនបានត្រួតពិនិត្យ និងមិនបានធ្វើសវនកម្ម) |
| ពន្ធលើប្រាក់ចំណេញក្នុងគ្រា | ២.៧៨៧.០៥៤ | ៥.៣១៨.៨៣៤ |
| ការកត់ត្រាបំណុលពន្ធពន្យារ | ៣.៧៤៨.៦៤៦ | - |
| និយ័តកម្មពន្ធក្នុងគ្រាមុនៗ | ៧៨៩.៣១៧ | - |
| | ៧.៣២៥.០១៧ | ៥.៣១៨.៨៣៤ |

**កំណត់សម្គាល់ព័ត៌មានហិរញ្ញវត្ថុសង្ខេប (មិនបានធ្វើសវនកម្ម)**
**សម្រាប់ដំណាច់ការិយបរិច្ឆេទ៦ខែ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧**

**២៨. ចំណាយពន្ធលើប្រាក់ចំណេញ (ត)**

**(ខ) ការផ្ទៀងផ្ទាត់ពន្ធលើប្រាក់ចំណេញ និងចំណេញគណនេយ្យ**

| | ដំណាច់ការិយបរិច្ឆេទ៦ខែ | |
|---|---|---|
| | **៣០ មិថុនា ២០១៧** | **៣០ មិថុនា ២០១៦** |
| | **ពាន់រៀល** | **ពាន់រៀល** |
| | (បានត្រួតពិនិត្យ ប៉ុន្តែមិនបានធ្វើសវនកម្ម) | (មិនបានត្រួតពិនិត្យ និងមិនបានធ្វើសវនកម្ម) |
| ចំណេញគណនេយ្យមុនបង់ពន្ធលើប្រាក់ចំណេញ | ៥.០៣៣.៥៨៤ | (៣០.៩៤៨.៣៦០) |
| ចំណាយមិនជាប់ពន្ធ | ២៥.៧៧៧.៨០១ | ៧.៥៤៤.៥១០ |
| លម្អៀងបណ្តោះអាសន្ន | (៦.៥៦៩.៤៩២) | ៤៩.៩៩៨.០១៩ |
| ខាតពន្ធយោងសម្រាប់តំបន់សេដ្ឋកិច្ច | ៣.៦២៨.៦៤៧ | - |
| ចំណេញជាប់ពន្ធ | ២៧.៨៧០.៥៤០ | ២៦.៥៩៤.១៦៩ |
| ពន្ធលើប្រាក់ចំណេញក្នុងអត្រា ២០% (*) | ២.៧៨៧.០៥៤ | ៥.៣១៨.៨៣៤ |
| ពន្ធលើប្រាក់ចំណេញក្នុងឆ្នាំ | ២.៧៨៧.០៥៤ | ៥.៣១៨.៨៣៤ |
| ការកត់ត្រាបំណុលពន្ធពន្យារ | ៣.៧៤៨.៦៤៦ | - |
| និយ័តកម្មពន្ធក្នុងគ្រាមុនៗ | ៧៨៩.៣១៧ | - |
| | ៧.៣២៥.០១៧ | ៥.៣១៨.៨៣៤ |

ពន្ធលើប្រាក់ចំណេញត្រូវបានគណនាតាមមូលដ្ឋានបំណកស្រាយបច្ចុប្បន្ននៃបទបញ្ញត្តិពន្ធដារ ក៏ប៉ុន្តែបទបញ្ញត្តិទាំងអស់នេះ អាចមានភាពប្រែប្រួលពីមួយគ្រាទៅមួយគ្រា ហើយការកំណត់ចុងក្រោយលើចំនួនពន្ធលើប្រាក់ចំណេញ នឹងត្រូវធ្វើឡើងបន្ទាប់ពីមានការត្រួតពិនិត្យរបស់អគ្គនាយកដ្ឋានពន្ធដារ។

(*) យោងតាមអនុក្រឹតលេខ ០១ អនក្រ.TT ចុះថ្ងៃទី០១ ខែមករា ឆ្នាំ២០១៥ ក.ស.ស បានទទួលការលើកលែងពន្ធរយៈពេលបីឆ្នាំ ពីគណៈកម្មការមូលបត្រកម្ពុជា។ ការលើកលែងពន្ធនេះ ត្រូវកាត់ ៥០% ពីពន្ធលើប្រាក់ចំណេញដែលបានបង់។

## កំណត់សម្គាល់ព័ត៌មានហិរញ្ញវត្ថុសង្ខេប (មិនបានធ្វើសវនកម្ម)
## សម្រាប់ដំណាច់ការិយបរិច្ឆេទ៦ខែ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧

**២៨. ចំណាយពន្ធលើប្រាក់ចំណេញ (ត)**

**(គ) ពន្ធពន្យារលើប្រាក់ចំណេញ**

| | ដំណាច់ការិយបរិច្ឆេទ៦ខែ | |
|---|---|---|
| | **៣០ មិថុនា ២០១៧** | **៣០ មិថុនា ២០១៦** |
| | **ពាន់រៀល** | **ពាន់រៀល** |
| | (បានត្រួតពិនិត្យ ប៉ុន្តែមិនបានធ្វើសវនកម្ម) | (មិនបានត្រួតពិនិត្យ និងមិនបានធ្វើសវនកម្ម) |
| សមតុល្យដើមឆ្នាំ | - | - |
| កត់ត្រាជាបន្ទុកក្នុងរបាយការណ៍ចំណេញ-ខាត | ៣.៧៤៨.៦៤៦ | - |
| សមតុល្យចុងឆ្នាំ | ៣.៧៤៨.៦៤៦ | - |

បម្រែបម្រួលពន្ធពន្យារទ្រព្យសកម្ម និងបំណុលពន្ធពន្យារក្នុងអំឡុងឆ្នាំ មានដូចខាងក្រោម៖

| <u>ពន្ធពន្យារទ្រព្យសកម្ម</u> | **អត្ថប្រយោជន៍ក្រោយពេលបញ្ចប់ការងារ ពាន់រៀល** | **សំវិធានធន ពាន់រៀល** | **ចំណូលពន្យារ ពាន់រៀល** | **ខាតជាប់ពន្ធយោងពីតំបន់សេដ្ឋកិច្ចពិសេស ពាន់រៀល** | **សរុប ពាន់រៀល** |
|---|---|---|---|---|---|
| នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៦ | - | - | - | - | - |
| កត់ត្រាជាបន្ទុកក្នុងរបាយការណ៍ចំណេញ-ខាត | ៨.១០៥.០២៨ | ១.៦៣១.៣២៩ | ១.១៩១.៦២៤ | ៤.៩៨៨.៣៤១ | ១៥.៩១៦.៣២២ |
| នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧ *(បានត្រួតពិនិត្យ ប៉ុន្តែមិនបានធ្វើសវនកម្ម)* | ៨.១០៥.០២៨ | ១.៦៣១.៣២៩ | ១.១៩១.៦២៤ | ៤.៩៨៨.៣៤១ | ១៥.៩១៦.៣២២ |

| <u>បំណុលពន្ធពន្យារ</u> | **រំលស់ពន្លឿន ពាន់រៀល** | **សរុប ពាន់រៀល** |
|---|---|---|
| នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៧ | - | - |
| កត់ត្រាជាបន្ទុកក្នុងរបាយការណ៍ចំណេញ-ខាត | (១៩.៦៦៤.៩៦៨) | (១៩.៦៦៤.៩៦៨) |
| នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧ *(បានត្រួតពិនិត្យ ប៉ុន្តែមិនបានធ្វើសវនកម្ម)* | (១៩.៦៦៤.៩៦៨) | (១៩.៦៦៤.៩៦៨) |

**កំណត់សម្គាល់ព័ត៌មានហិរញ្ញវត្ថុសង្ខេប ( មិនបានធ្វើសវនកម្ម )**
**សម្រាប់ដំណាច់ការិយបរិច្ឆេទ៦ខែ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧**

## ២៩. ចំណេញ/( ខាត ) ក្នុងមួយភាគហ៊ុន

### ( ក ) ចំណេញ/( ខាត )ក្នុងមួយភាគហ៊ុនមូលដ្ឋាន

ចំណេញក្នុងមួយភាគហ៊ុនមូលដ្ឋានត្រូវបានគណនា ដោយយកប្រាក់ចំណេញដែលត្រូវបែងចែកឱ្យម្ចាស់មូលធនរបស់ ក.ស.ស ចែកនឹងចំនួនភាគហ៊ុនមធ្យម ក្នុងអំឡុងការិយបរិច្ឆេទចេញផ្សាយភាគហ៊ុន។

| | ដំណាច់ការិយបរិច្ឆេទ៣ខែ | | ដំណាច់ការិយបរិច្ឆេទ៦ខែ | |
|---|---|---|---|---|
| | **៣០ មិថុនា ២០១៧** | **៣០ មិថុនា ២០១៦** | **៣០ មិថុនា ២០១៧** | **៣០ មិថុនា ២០១៦** |
| | *(បានត្រួតពិនិត្យប៉ុន្តែ មិនបានធ្វើសវនកម្ម)* | *(មិនបានត្រួតពិនិត្យ និងមិនបានធ្វើវនកម្ម)* | *(បានត្រួតពិនិត្យប៉ុន្តែ មិនបានធ្វើសវនកម្ម)* | *(មិនបានត្រួតពិនិត្យនិង មិនបានធ្វើវនកម្ម)* |
| ចំណេញ/(ខាត)របស់ភាគហ៊ុនិក (ពាន់រៀល) | ៤៨៨.៦៧៩ | (៣០.៣៥៩.១២៥) | (២.២៩១.៤៣៣) | (៣៦.២៦៧.១៩៤) |
| ចំនួនភាគហ៊ុនមធ្យម | ៨៥.៧៧១.៩៦៧ | ៦៤.៣២៨.៩៧៥ | ៨៥.៧៧១.៩៦៧ | ៦៤.៣២៨.៩៧៥ |
| ចំណេញ/(ខាត)ក្នុងមួយភាគហ៊ុន មូលដ្ឋាន (រៀល) | ៥,៧០ | (៤៧១,៩៤) | (២៦,៧២) | (៥៦៣,៧៨) |

### ( ខ ) ចំណេញក្នុងមួយភាគហ៊ុនថយចុះ ( diluted earnings per share )

ចំណេញក្នុងមួយភាគហ៊ុនថយចុះ ត្រូវបានគណនាដោយកែប្រែចំនួនមធ្យមនៃភាគហ៊ុនធម្មតាដែលមាន ដោយសន្មត ថាមានការផ្ទេរភាគហ៊ុនដែលមានសក្តានុពលទាំងអស់ទៅជាភាគហ៊ុនធម្មតា។ គិតត្រឹមដំណាច់ការិយបរិច្ឆេទនេះ ក.ស.ស មិន មានភាគហ៊ុនដែលមានសក្តានុពលអាចផ្ទេរទៅជាភាគហ៊ុនធម្មតានោះទេ។ ដូចនេះ ចំណេញក្នុងមួយភាគហ៊ុនថយចុះ គឺមានតម្លៃ ស្មើនឹងចំណេញក្នុងមួយភាគហ៊ុនមូលដ្ឋាន។

**កំណត់សម្គាល់ព័ត៌មានហិរញ្ញវត្ថុសង្ខេប ( មិនបានធ្វើសវនកម្ម )**
**សម្រាប់ជំណាច់ការិយបរិច្ឆេទ៦ខែ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧**

## ៣០. សាច់ប្រាក់បានពីប្រតិបត្តិការ

| | ជំណាច់ការិយបរិច្ឆេទ៦ខែ | |
|---|---|---|
| | **៣០ មិថុនា ២០១៧ ពាន់រៀល** | **៣០ មិថុនា ២០១៦ ពាន់រៀល** |
| | (បានត្រួតពិនិត្យ ប៉ុន្តែមិនបានធ្វើសវនកម្ម) | (មិនបានត្រួតពិនិត្យ និងមិនបានធ្វើសវនកម្ម) |
| ចំណេញ/(ខាត)មុនបង់ពន្ធលើប្រាក់ចំណេញ | ៥.០៣៣.៥៨៤ | (៣០.៩៤៨.៣៦០) |
| *និយ័តកម្ម៖* | | |
| រំលស់ទ្រព្យសម្បត្តិ និងបរិក្ខារ និងរំលស់ទ្រព្យសកម្មអរូបី | ១១.៥៥១.១៨៨ | ១០.៧៦២.៨៧៣ |
| ចំណាយការប្រាក់ - សុទ្ធ | ២៤.៧៩៩.២១៧ | ៦៤.៨៤១.៤០៧ |
| ចំណាយកាតព្វកិច្ចអត្ថប្រយោជន៍សោធននិវត្តន៍ | ២.០៧៧.០០០ | ២.០៣២.៥០០ |
| *បម្រែបម្រួលដើមទុនបង្វិល៖* | | |
| សន្និធិ | (២១៩.៤៧៥) | (៩១.០៨៦) |
| គណនីអតិថិជនពាណិជ្ជកម្ម និងគណនីអតិថិជនផ្សេងៗ | (៦.៤០៤.៦២៧) | (២.២២៣.៤៤៦) |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីអ្នកផ្គត់ផ្គង់ផ្សេងៗ | ៤៩៧.០៧៧ | (៦.៣២៤.៤៨០) |
| ចំណូលពន្យារ | ១៦០.៨៩៤ | (១៥.២១៣) |
| សាច់ប្រាក់បានពីប្រតិបត្តិការ | ៣៧.៤៩៤.៨៥៨ | ៣៨.០៣៤.១៩៥ |

**កំណត់សម្គាល់ព័ត៌មានហិរញ្ញវត្ថុសង្ខេប (មិនបានធ្វើសវនកម្ម)**
**សម្រាប់ដំណាច់ការិយបរិច្ឆេទ៦ខែ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧**

## ៣១. ប្រតិបត្តិការភាគីពាក់ព័ន្ធ

### (ក) ប្រតិបត្តិការ និងសមតុល្យភាគីពាក់ព័ន្ធ

ក.ស.ស ស្ថិតក្រោមការគ្រប់គ្រងផ្នែកហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងស្ថិតនៅក្រោមការគ្រប់គ្រងផ្នែកបច្ចេកទេសរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន។

ប្រតិបត្តិការ និងសមតុល្យភាគីពាក់ព័ន្ធសំខាន់ៗជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទាក់ទិននឹងប្រាក់កម្ចី ត្រូវបានលាតត្រដាងក្នុងកំណត់សម្គាល់ ១៦។

### (ខ) ការទូទាត់ជូនគណៈគ្រប់គ្រងសំខាន់ៗ

ការទូទាត់ជូនគណៈគ្រប់គ្រងសំខាន់ៗ សម្រាប់ដំណាច់ការិយបរិច្ឆេទ៦ខែ ថ្ងៃទី៣០ ខែមិថុនា មានដូចខាងក្រោម៖

| | ដំណាច់ការិយបរិច្ឆេទ៦ខែ | |
|---|---|---|
| | ៣០ មិថុនា ២០១៧ ពាន់រៀល | ៣០ មិថុនា ២០១៦ ពាន់រៀល |
| | (បានត្រួតពិនិត្យ ប៉ុន្តែមិនបានធ្វើសវនកម្ម) | (មិនបានត្រួតពិនិត្យ និងមិនបានធ្វើសវនកម្ម) |
| *ក្រុមប្រឹក្សាភិបាល* | | |
| ប្រាក់បៀវត្សរ៍ កម្រៃ និងចំណាយពាក់ព័ន្ធផ្សេងៗ | ៦៩៨.៤០០ | ២៦៣.១៦០ |
| *បុគ្គលិកថ្នាក់គ្រប់គ្រងសំខាន់ៗ* | | |
| ប្រាក់បៀវត្សរ៍ និងចំណាយផ្សេងៗ | ៧៦០.៧៦២ | ៥១១.៩១០ |
| អត្ថប្រយោជន៍សោធននិវត្តន៍ (*) | ៧៦.៨៩១ | ៥០.៧២១ |

បុគ្គលិកថ្នាក់គ្រប់គ្រងសំខាន់ៗ រួមមានអគ្គនាយក និងនាយកប្រតិបត្តិ ដែលជាអ្នកសម្រេចចិត្តជាយុទ្ធសាស្រ្ត លើការដឹកនាំ លើផ្នែកហិរញ្ញវត្ថុ និងប្រតិបត្តិការរបស់ ក.ស.ស ។

(*) គម្រោងអត្ថប្រយោជន៍សោធននិវត្តន៍ ត្រូវបានដាក់ឱ្យប្រតិបត្តិក្នុងអង្គភាពទាំងមូល ក្នុងនោះបុគ្គលិកថ្នាក់គ្រប់គ្រងសំខាន់ៗក៏មានសិទ្ធិទទួលគម្រោងអត្ថប្រយោជន៍នេះ ដូចគ្នានឹងបុគ្គលិក ក.ស.ស ដទៃទៀតដែរ។

## ៣២. កិច្ចសន្យា

គិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧ ក.ស.ស មានកិច្ចសន្យាទាក់ទិននឹងការទិញទ្រព្យសម្បត្តិមិនទាន់ទូទាត់ចំនួន ១៥២.៥៩៩លានរៀល (២០១៦ ៖ ១៧០.៩២១លានរៀល) ចំពោះការទិញទ្រព្យសម្បត្តិ និងបរិក្ខារ ដែលត្រូវបង់ក្នុងដំណាក់កាលផ្សេងៗ រហូតដល់ឆ្នាំ២០១៨។